**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ថោង ចាន់ថាត**

**ជា ហ្វីលីព**

ណែនាំដោយ

លោកស្រី **សំណាង ផលដេត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ជាកិច្ចដំបូងយើងខ្ញុំទាំងពីរនាក់ **ថោង ចាន់ថាត** និង **ជា ហ្វីលីព** សូមគោរពនូវការដឹងគុណដល់ **លោកឪពុក និងអ្នកម្តាយ** ជាអ្នកមានគុណមិនអាចកាត់ថ្លៃបាន កូនសូមអរគុណដែលបានចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីនៅក្នុងផ្ទៃរហូតដល់ថ្ងៃចាប់កំណើតរហូតមកដល់សព្វថ្ងៃនេះពោពេញដោយក្តីស្រលាញ់ ការសណ្តោសប្រណីកូន និងមានព្រហ្មវិហារធម៌ អប់រំទូន្មានកូនឲ្យក្លាយជាកូនល្អ សិស្សល្អ មនុស្សល្អនៅក្នុងសង្គម។ ជាពិសេសឧបត្ថមទំនុបបម្រុងឲ្យកូនបានរៀនសូត្រតាំងថ្នាក់មតេយ្យរហូតមកដល់ថ្នាក់បរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងរយៈពេលកន្លងរហូតមកនេះលោកទាំងបួនពុំដែលត្អូញត្អែរពីការហត់នឿយបន្តិចសោះណាឡើយ ផ្ទុយទៅវិញលោកទាំងបួនមានតែណែនាំកូនឲ្យខិតខំរៀនសូត្រ និងបញ្ចប់ការសិក្សាឲ្យបានជោគជ័យ។

ខ្ញុំបាទ **ថោង ចាន់ថាត** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **អង្គការសម្រេចសុបិនកុមារកម្ពុជា** ដែលបានផ្តល់អាហារូបករណ៍ឲ្យខ្ញុំបាទបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រក្នុងរយៈពេលបួនឆ្នាំមកនេះ ដោយផ្តល់ទាំងថ្លៃបង់សាលាទាំងការស្នាក់នៅ ការចំណាយប្រចាំថ្ងៃ និងការចំណាយផ្សេងៗទៀតដល់រូបខ្ញុំបាទសម្រាប់ការសិក្សារយៈពេលបួនឆ្នាំពេញមកនេះ។

យើងខ្ញុំសូមថ្លែងអំណគុណចំពោះ **ឯកឧត្តមសាលវិទ្យាការ និងសាកលវិទ្យាការរង ព្រឹទ្ធបុរស និងលោក លោកស្រី សាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ចំណាយពេលវេលា និងកម្លាំងញើសឈាមដ៏មានតម្លៃរបស់អស់លោកដើម្បីបណ្តុះបណ្តាល និងផ្តល់នូវពុទ្ធិដល់រូបខ្ញុំទាំងពីរនាក់ក៏ដូចជាមិត្តនិស្សិតផ្សេងទៀតដែលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចតាំងពីថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់ការសិក្សា។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកស្រីសាស្រ្តាចារ្យ សំណាង ផលដេត** ដែលលោកស្រីជាសាស្រ្តាចារ្យដឹកនាំការសរសេរសារណាបញ្ចប់របស់យើងខ្ញុំទាំងពីរ ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃទាំងកម្លាំងកាយ និងកម្លាំងចិត្តដើម្បីបណ្តុះបណ្តាល ពន្យល់ណែនាំ បង្ហាត់បង្ហាញផ្លូវក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះឡើងបានដោយជោគជ័យ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់សូមគោរពជូនពរដល់ **លោកអ្នកមានគុណរបស់ខ្ញុំទាំងពីររូប ឯកឧត្តមសាកលវិទ្យាការ សាកលវិទ្យាការរង និងព្រឹទ្ធបុរស និងលោក លោកស្រី សាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់** សូមជួបតែសំណាងល្អ មានសុខភាពមាំមួនជោគជ័យគ្រប់ភារកិច្ច និងជួបតែពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការសិក្សាអស់រយៈពេលចំនួនបួនឆ្នាំកន្លងមកនៅសាកលវិទ្យាសាស្រ្តភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានផ្តល់ចំណេះដឹងជាច្រើនដល់ពួកខ្ញុំក្រេបជញ្ជក់សម្រាប់ដើម្បីប្រើប្រាស់នាថ្ងៃអនាគត ។ ក្នុងឳកាសនេះសាកលវិទ្យាល័យ ក៏បានផ្តល់ឳកាសមួយដ៏កម្ររកបានដោយអោយ ពួកខ្ញុំធ្វើការសិក្សាស្រាវជ្រាវចងក្រង នូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមួយនេះផងដែរ ។ ទន្ទឹមនឹងនេះ ពួកខ្ញុំក៏បានលើកយកនូវប្រធានបទស្តីអំពី "**នីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ**" មកធ្វើការរៀបរៀងសរសេរតាក់តែងឡើង ដើម្បីជាការចែករំលែកនូវចំណេះដឹងបន្ថែមទៀតដល់មិត្តរួមថ្នាក់ ព្រមទាំងអ្នកអានគ្រប់ៗគ្នាទៅតាមសមត្ថភាព និង ចំណេះដឹងដែលពួកខ្ញុំមាន។

ការលើកយកប្រធានបទនេះមកតាក់តែងជាសារណា គឺក្នុងគោលបំណងពង្រីកចំណេះដឹងបន្ថែមដល់និស្សិតគ្រប់មជ្ឈដ្ឋានឲ្យយល់កាន់តែច្បាស់អំពីនីតិវិធី លក្ខខណ្ឌ និងប្រព័ន្ធទ្រព្យសម្បត្តិក្នុងដំណើរការអាពាហ៍ពិពាហ៍ ក៏ដូចជាវិធីបញ្ចប់អាពាហ៍ពិពាហ៍ផងដែរ។ ការយល់ដឹងនេះអាចចូលរួមចំណែកក្នុងការផ្តល់ចំណេះដឹងដល់និស្សិតនិងមិត្តអ្នកអានគ្រប់គ្នាស្វែងយល់កាន់តែស៊ីជម្រៅ និងច្បាស់លាស់អំពីដំណើរការនៃនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៃព្រះរាជាណាចក្រកម្ពុជារបស់យើងដែលប្រារព្ធធ្វើឡើងតាមប្រពៃណីជាតិ បន្ទាប់ពីបានសុំការអនុញ្ញាតច្បាប់ ពិធីរៀបមង្គលការ គឺជាពិធីមួយដែលរៀបចំឡើងសម្រាប់ផ្សំផ្គុំមនុស្សប្រុស ស្រីឲ្យក្លាយជាប្តីប្រពន្ធ។ ម្យ៉ាងវិញទៀត ការស្វែងយល់នេះ ជាការធានានូវសុខុមាលភាពរបស់ប្រជាពលរដ្ឋគ្រប់ៗរូប ដែលមានបំណងកសាងគ្រួសារឲ្យបានរឹងមាំ មានសុភមង្គល និងធានាការចិញ្ចឹមបីបាច់ថែរក្សាអប់រំកូនរបស់គេបានល្អប្រសើរ។

តាមរយៈសៀវភៅមួយនេះ អាចនឹងនៅមានចំណុចខ្វះខាតច្រើន ព្រោះថាសៀវភៅនេះគឺត្រូវបានសង្ខេបនឹងសម្រាយយកតែខ្លឹមសារមួយចំនួនដែលទាក់ទងទៅនឹងប្រធានបទតែប៉ុណ្ណោះ។ ដូចនេះចំពោះខ្លឹមសារ អត្ថន័យ អក្ខរាវិរុទ្ធ ឃ្លា ក្បួនខ្នាត វេយ្យាករណ៍ និងការរចនាច្បាស់ជាត្រូវការកែតម្រូវដើម្បីជួយឲ្យសៀវភៅនេះកាន់តែល្អ និងមានភាពសុក្រិត។

ជាចុងក្រោយ ពួកខ្ញុំសូមទទួលរាល់មតិយោបល់ដោយអនុគ្រោះពីសំណាក់អស់លោក លោកស្រី សាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ អ្នកអានគ្រប់ៗគ្នា ដើម្បីកែតម្រូវ និងអភិវឌ្ឍន៍សៀវភៅនេះឲ្យកាន់តែល្អប្រសើរឡើង។ ពួកខ្ញុំសូមគោរពជូនពរ សាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ អ្នកអានគ្រប់ៗគ្នា សំណាងល្អគ្រប់ពេលវេលា ព្រមទាំងជោគជ័យលើគ្រប់ភារកិច្ច និង ជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

១.លំនាំបញ្ហា ........ ១

២.ចំណោទបញ្ហា ........ ២

៣.គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រក្នុងការស្រាជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១៖ សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍**

**១.១ ពិធីមុនរៀបអាពាហ៍ពិពាហ៍** ........ ៤

១.១.១ ពិធីកំជាប់ពាក្យ ឬភ្ជាប់ពាក្យ ........ ៤

១.១.២ លក្ខខណ្ឌនៃកំជាប់ពាក្យតាមបែបប្រពៃណី ........ ៤

១.១.៣ លក្ខខណ្ឌតាមផ្លូវច្បាប់នៃកំជាប់ពាក្យ ........ ៥

១.១.៤ ការមិនកំណត់អាយុនៃពិធីកំជាប់ពាក្យ ........ ៥

**១.២ ករណីរំលាយពិធីកំជាប់ពាក្យ** ........ ៥

១.២.១ ការរំលាយពិធីកំជាប់ពាក្យ ........ ៥

១.២.២ ការធ្វើបណ្តឹងទាមទារសំណងនៃការខូចខាតនៃការរំលាយ ........ ៦

១.២.៣ អំឡុងពេលធ្វើបណ្តឹងនៃការរំលាយ ........ ៧

**១.៣ លក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍** ........ ៧

១.៣.១ និយមន័យនៃអាពាហ៍ពិពាហ៍ ........ ៧

១.៣.២ លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍ ........ ៧

១.៣.៣ លក្ខខណ្ឌនៃអាយុនៃភាគី ..................................... ៨

១.៣.៤ ការកំណត់ភេទនៃភាគី..................................... ៩

១.៣.៥ គោលការណ៍ស្ម័គ្រចិត្តនៃភាគី ..................................... ៩

**១.៤ អាពាហ៍ពិពាហ៍របស់ជនត្រូវបានកម្រិតសមត្ថភាព** ..................................... ៩

១.៤.១ ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន ..................................... ៩

១.៤.២ ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ(ជនវិកលចរិក) ..................................... ១០

១.៤.៣ ការរៀបអាពាហ៍ពិពាហ៍របស់បុគ្គលដែលទទួលបានអត្ថាធិករា ..................................... ១១

**១.៥ ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍** ..................................... ១២

១.៥.១ ការហាមឃាត់មិនឲ្យមានទ្វេពន្ធភាព ..................................... ១២

១.៥.២ កំឡុងពេលហាមឃាត់របស់ស្ត្រីមិនឲ្យរៀបអាពាហ៍ពិពាហ៍..................................... ១៣

១.៥.៣ ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍នៃញាតិលោហិត..................................... ១៤

១.៥.៤ ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍នៃញាតិពន្ធ ..................................... ១៥

**ជំពូកទី២៖ នីតិវិធីនៃការបង្កើតអាពាហ៍ពិពាហ៍**

**២.១ លក្ខខណ្ឌទម្រង់អាពាហ៍ពិពាហ៍**..................................... ១៨

២.១.១ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ..................................... ១៨

២.១.២ បណ្ណប្រកាសជាសាធារណៈ ..................................... ១៨

២.១.៣ រយៈពេលនៃការរងចាំ..................................... ១៩

២.១.៤ បុគ្គលដែលអាចប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍ ..................................... ១៩

២.១.៥ មូលហេតុនៃការប្ដឹងជំទាស់នៃអាពាហ៍ពិពាហ៍..................................... ២០

**២.២ ការចុះសុំបុត្រអាពាហ៍ពិពាហ៍**..................................... ២០

២.២.១ អំពីមន្ត្រីទទួលបន្ទុក..................................... ២០

២.២.២ អំពីសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍..................................... ២០

២.២.៣ ឯកសារពាក់ព័ន្ធ ........ ២១
២.២.៤ ការចុះបញ្ជីអាពាហ៍ពិពាហ៍ ........ ២១
២.២.៥ ការចេញ ឬការផ្ដល់សុំបុត្រអាពាហ៍ពិពាហ៍ ........ ២១
**២.៣ អានុភាពនៃអាពាហ៍ពិពាហ៍** ........ ២២
២.៣.១ ការប្រើនាមត្រកូលរបស់ប្ដីប្រពន្ធ ........ ២២
២.៣.២ សេរីភាពក្នុងការប្រកបវិជ្ជាជីវៈ និងសិទ្ធិចូលរួមក្នុងសកម្មភាពសង្គម ........ ២២
២.៣.៣ ករណីកិច្ចរួមរស់ សហការ និងសង្គ្រោះគ្នាទៅវិញទៅមក ........ ២៣
២.៣.៤ តម្លៃនៃការងារក្នុងផ្ទះ ........ ២៣
២.៣.៥ ករណីកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូន ........ ២៣
**២.៤ ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធ** ........ ២៤
២.៤.១ កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ........ ២៤
២.៤.២ ប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់ ........ ២៥
២.៤.៣ ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច ........ ២៨
២.៤.៤ ការចាត់ចែងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ........ ២៨
២.៤.៥ ការស្នាក់អាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក ........ ២៩
**២.៥ មូលហេតុបញ្ចប់អាពាហ៍ពិពាហ៍** ........ ២៩
២.៥.១ មរណភាពរបស់សហព័ទ្ធ ........ ២៩
២.៥.២ មោឃភាពអាពាហ៍ពិពាហ៍ ........ ៣០
២.៥.៣ ការលុបចោលអាពាហ៍ពិពាហ៍ ........ ៣១
២.៥.៤ អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ ........ ៣២
២.៥.៥ អវត្តមាន ឬការប្រកាសការបាត់ខ្លួន ........ ៣៣
២.៥.៦ ការលែងលះ ........ ៣៥

**សេចក្តីសន្និដ្ឋាន** ........................................................................................ ៣៧
**អនុសាសន៍** .................................................................................................. ៣៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

អាពាហ៍ពិពាហ៍គឺជាពិធីមួយដែលមានតាំងពីសម័យបុរាណកាលមកម្លេះ ដែលគេតែងហៅថាការរៀបការ។ ដោយពិធីរៀបអាពាហ៍ពិពាហ៍នេះគឺជាពិធីមួយដែលកំណត់ឲ្យមនុស្សពីរនាក់បានរួមរស់នៅជាមួយគ្នាបង្កើតបានជាគ្រួសារបន្តពូជពង្សត្រកូលជាកូនជាចៅដោយមានមានកាតព្វកិច្ចសហការជួយសង្គ្រោះគ្នាទៅវិញទៅមក។ ជាធម្មតាមុននឹងឈានចូលដល់ពិធីនេះគឺនៅមានពិធីមួយទៀតដែលគេតែងប្រារព្ធឡើងនោះគឺជាពិធីកំជាប់ពាក្យឬពិធីភ្ជាប់ពាក្យ។ ពិធីនេះគឺជាការលើកជំនួនខាងកូនប្រុសទៅចូលស្តីដណ្តឹងខាងកូនស្រី ដែលជាការពាក់ជញ្ជៀនឲ្យគ្នាទៅវិញទៅមករវាងកូនប្រុសស្រីទាំងសងខាង។ នៅក្នុងដំណាក់កាលនៃពិធីភ្ជាប់ពាក្យនេះគឺគេមិនបានកំណត់នៃអាយុនៃកូនប្រុសស្រីដែលត្រូវភ្ជាប់ពាក្យនោះទេ គឺឲ្យតែភាគីទាំងពីរអាចភ្ជាប់បានមុនដល់នីតិភាពនៃការរៀបអាពាហ៍ក៏បានឬដល់ពេលនីតិភាពក៏បាន។ ការភ្ជាប់ពាក្យគឺជាការសន្យាមួយដែលភាគីនៃកំជាប់ពាក្យថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅថ្ងៃខាងមុខ។ ក្នុងកំឡុងពេលកំជាប់ពាក្យនេះផងដែរគឺជាការសន្មត់ថាកូនប្រុសស្រីទាំងពីរគឺមានម្ចាស់គូកំណានចិត្តរួចហើយមិនមែននៅទំនេរនោះទេ ដូច្នេះភាគីទាំងពីរមិនអាចទៅពាក់ព័ន្ធជាមួយអ្នកដទៃបាននោះទេ។ ប្រសិនបើមានភាគីណាម្យ៉ាងមានបំណងចង់រំលាយពិធីភ្ជាប់ពាក្យនេះដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីម្យ៉ាងទៀតអាចទាមទារសំណងនៃការរំលាយពិធីនេះបានផងដែរ។

បច្ចុប្បន្នកម្ពុជាកំពុងមានកំណើនប្រជាជនកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ការកើនឡើងនៃកំណើនប្រជាជននេះគឺបណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍នៃប្រពលរដ្ឋជាច្រើនគ្រួសារក្នុងមួយឆ្នាំៗ ប៉ុន្តែការរៀបអាពាហ៍ពិពាហ៍នោះ យើងមិនអាចសន្មត់បានទេថាជាការរៀបការស្របតាបច្បាប់ឬមិនស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន។ ប្រជាពលរដ្ឋមួយចំនួនមិនទាន់បានជ្រាបនៅឡើយទេ អំពីអាពាហ៍ពិពាហ៍មួយដែលមានលក្ខខណ្ឌស្របច្បាប់ និងទទួលស្គាល់ដោយច្បាប់ ភាគច្រើនការរៀបការគឺធ្វើឡើងដោយមានការរៀបចំពិធីតាមបែបប្រពៃណីដោយធ្វើជាពិធីដ៏ឱឡារឹកដោយមានការដឹងលឺពីសំណាក់សាធារណជនជាការគ្រប់គ្រាន់ដោយពុំបានឈ្វេងយល់អំពីលក្ខខណ្ឌមួយចំនួនអំពីនីតិវិធីនេះការរៀបការច្បាប់ ឬដោយមានការភាន់ច្រឡំអំពីលិខិតដែលអនុញ្ញាត្តឲ្យរៀបអាពាហ៍ពិពាហ៍ដែលចេញដោយអាជ្ញាធរថាជាអត្រានុកូលដ្ឋាឬសុំបុត្រនៃអាពាហ៍ពិពាហ៍ជាដើម។

ដោយយោងតាមច្បាប់កម្ពុជាដែលជាធរមានបច្ចុបប្បន្ន ដើម្បីរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែភាគីនៃអាពាហ៍ពិពាហ៍មានការស្ម័គ្រចិត្តដោយព្រមព្រៀងដោយគ្មានការបង្ខិតបង្ខំ ជាពិសេសគឺពឹងផ្អែកទៅលើ

លក្ខខណ្ឌនៃអាយុភាគី។ ការកំណត់អាយុនេះគឺជាធាតុដ៏សំខាន់បំផុតនៃអាពាហ៍ពិពាហ៍ ពីព្រោះថាការទទួលស្គាល់នៃអាយុគឺជាការទទួលខុសត្រូវរបស់គីដែលមានការយល់ដឹងចេះគិតពិចារណាមានទំនួលខុសត្រូវលើគ្រួសារ។ បន្ថែមពីលើលក្ខខណ្ឌនៃអាយុនេះទៀតនោះនៅមានលក្ខខណ្ឌចម្បងៗមួយចំនួនទៀតដែលធ្វើឲ្យអាពាហ៍ពិពាហ៍មួយមានលក្ខណៈស្របច្បាប់ និងទទួលស្គាល់ដោយច្បាប់ ដោយលក្ខខណ្ឌទាំងនោះរួមមានដូចជា ការកំណត់ភេទនៃភាគី ការហាមឃាត់មិនឲ្យរៀបការរវាងញាត្តិលោហិតឬញាត្តិពន្ធ ការរៀបការនៃជនដែលត្រូវបានកម្រិតសមត្ថភាព និងការហាមឃាត់មិនឲ្យមានទ្វេពន្ធភាពជាដើម។

## ២.ចំណោទបញ្ហា

ដោយសម្លឹងឃើញពីកំណើននៃប្រជាជនក៏ដូចជាកំណើននៃគ្រួសារមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមយួយឆ្នាំ ប៉ុន្តែការរៀបអាពាហ៍ពិពាហ៍នោះ គឺមិនបានឈ្វេងយល់អំពីនីតិវិធី ក៏ដូចជាលក្ខខណ្ឌនៃច្បាប់តម្រូវឲ្យអាពាហ៍ពិពាហ៍មួយមានលក្ខណៈត្រឹមត្រូវទៅតាមច្បាប់ឬបទដ្ឋានគតិយុត្តផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា គឺជាហេតុនាំឲ្យមានគ្រួសារមួយចំនួននៅតែបន្តការរៀបអាពាហ៍ពិពាហ៍ដែលមានលក្ខណៈមិនស្រប់ច្បាប់ពេញលេញជាបន្តបន្ទាប់។ ការនៅតែបន្តមិនបានឈ្វេងយល់និងអនុវត្តឲ្យសមស្របទៅតាមផ្លូវច្បាប់បែបនេះវាអាចបណ្តាលឲ្យមានផលវិបាកនៅពេលមានបញ្ហាកើតឡើងនៅក្នុងគ្រួសារ និងជះឥទ្ធិពលទៅដល់ស្មារតីនៃច្បាប់ដែលបានកំណត់ទុកជាមុនសម្រាប់យកទៅអនុវត្តន៍ ដើម្បបីចៀសវៀងមានបញ្ហាចោទឡើងនៅពេលមានទំនាស់ក្នុងគ្រួសារកើតឡើងដោយរូបភាពណាមួយនៅថ្ងៃខាងមុខ។

បញ្ហាទាំងនេះគឺស្តែងឡើងដោយសារការខ្វះខាតចំណេះដឹងផ្នែកបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធរបស់ប្រជាពលរដ្ឋដែលបានរៀបអាពាហ៍ពិពាហ៍រួចមកហើយដោយមិនបានអនុវត្តទៅតាមគោលបំណងនៃច្បាប់។ បញ្ហាចោទឡើងត្រង់ថា ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយមានលក្ខខណៈសមស្របជាមួយច្បាប់ ថាតើមានលក្ខខណ្ឌអ្វីខ្លះ? មាននីតិវិធីបែបណាខ្លះ? ត្រូវធ្វើជាមួយស្ថាប័នណាខ្លះ? ទើបអាពាហ៍ពិពាហ៍មួយនោះត្រឹមត្រូវទៅច្បាប់ផ្លូវច្បាប់?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងនៃការស្រាវជ្រាវនេះគឺដើម្បីសិក្សាឈ្វេងយល់បានកាន់តែច្បាស់ និងស៊ីជម្រៅអំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ក៏ដូចជាការឆ្លើយតបទៅនឹងបញ្ហាដែលតែងចោទឡើង និងកំពុងចោទមានឡើងនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ននទាក់ទងនងការរៀបអាពាហ៍ពិពាហ៍មួយឲ្យត្រឹមត្រូវតាមច្បាប់ និងជាពិសេសទុកជាឯកសារដល់អ្នកសិក្សាជំនាន់ក្រោយៗទៀតទុកជាទឡ្ហីករណ៍សម្រាប់ការសិក្សាស្រាវជ្រាវអំពីនីតិវិធីរៀបអាពាហ៍ពិពាហ៍។

**គោលបំណងចម្បងសំខាន់ៗរួមមាន៖**

- ស្វែងយល់អំពីលក្ខខណ្ឌផ្សេងៗនៃការរៀបអាពាហ៍ពិពាហ៍
- ស្វែងយល់អំពីច្បាប់បទដ្ឋានគតិយុត្តនានាដែលមានធរមាននៅកម្ពុជាបច្ចុប្បន្ន
- ស្វែងយល់អំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ
- ស្វែងយល់អំពីលក្ខខណ្ឌមួយចំនួននៃអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវទៅតាមច្បាប់
- ទុកជាឯកសារ និងចែករំលែកទៅដល់មិត្តនិស្សិត អ្នកសិក្សាស្រាវជ្រាវ និងជាពិសេសសម្រាប់ប្អូនៗជំនាន់ក្រោយៗទៀត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទមួយនេះគឺពឹងផ្អែកអាស្រ័យទៅលើលិខិតបទដ្ឋានគតិយុត្តច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយរួមមានដូចជា៖ រដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី អនុក្រឹត្យ និងសេចក្តីប្រកាសផ្សេងៗទៀត។

## ៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ

សារៈប្រយោជន៍ក៏ដូចជាសារៈសំខាន់នៃប្រធានបទនេះ គឺសម្រាប់សាធារណជន មិត្តនិស្សិត ដ៏ដូចជាអ្នកសិក្សាស្រាជ្រាវ ជាពិសេសអ្នកសិក្សាផ្នែកនីតិសាស្ត្រទាំងអស់ទុកជាឯកសារអត្ថបទសម្រាប់យកទៅសិក្សាស្វែងយល់ជាពុទ្ធិបន្ថែមទៀតក្នុងការសិក្សារៀនសូត្រ។ជាពិសេសគឺសម្រាប់សាធារណជនដែលមាននបំណង និងគ្រោងរៀបអាពាហ៍ពិពាហ៍ បានស្វែងយល់អំពីលក្ខខណ្ឌគ្រិះមួយចំនួន និងនីតិវិធីនានានៃការរៀបអាពាហ៍ពិពាហ៍មួយមិនផ្ទុយនឹងច្បាប់ និងជាដំណោះស្រាយដ៏ល្អសម្រាប់ រាល់បញ្ហាកើតឡើងក្រោមរូបភាពណាមួយនៅក្នុងកំឡុងពេលនៃអាពាហ៍ពិពាហ៍។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ការសរសេរសារណានេះឡើងបានគឺពឹងផ្អែកលើ សុំយោបល់ពីសាស្ត្រាចារ្យដឹកនាំ សុំមតិយោបល់ពីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងដកស្រង់អត្ថបទច្បាប់ បទដ្ឋានគតិយុត្ត អនុក្រឹត្យ និងប្រកាសនានារបស់រាជរដ្ឋាភិបាលដែលទាក់ទងនិងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍។ ចំពោះឯកសារដែលទទួលបានៗមកពីសាលាសង្កាត់ សៀវភៅរបស់សាស្ត្រាចារ្យដែលមានបទពិសោធន៍បង្រៀនច្រើនឆ្នាំ ពីបណ្ណាល័យពីប្រព័ន្ធអ៊ីនធើណែត និងច្បាប់ធរមានបច្ចុប្បន្ន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសរសេរប្រធានបទមួយនេះយើងខ្ញុំបានបែងចែកប្រធានបទមួយនេះជាពីរជំពូក ដោយជំពូកទី១ យើងនិយាយអំពី សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍ និងជំពូកទី២ យើងនិយាយអំពីនីតិវិធីនៃការបង្កើតអាពាហ៍ពិពាហ៍។ ចំពោះខ្លឹមសារពីសស្តារយើងនឹងបកស្រាយលម្អិតនៅក្នុងអត្ថបទទាំងមូលនៃសារណានេះ។

# ជំពូកទី១៖ សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

# ជំពូកទី១៖ សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

## ១.១ ពិធីមុនរៀបអាពាហ៍ពិពាហ៍

### ១.១.១ ពិធីកំជាប់ពាក្យ ឬភ្ជាប់ពាក្យ

ជាទូទៅតាមទំនៀមទម្លាប់ ប្រពៃណីកម្ពុជាមុនពេលរៀបអាពាហ៍ពិពាហ៍ គឺត្រូវធ្វើពិធីកំជាប់ពាក្យ។ មិនថាប្រពៃណី ឬក៏ទំនៀមទម្លាប់នោះទេ ពិធីនេះក៏ច្បាប់កម្ពុជាទទួលស្គាល់ដែរ បើទោះបីជាច្បាប់មិនចែងថាទុកថា លុះត្រាតែធ្វើពិធីនេះទើបអាពាហ៍ពិពាហ៍មានអានុភាពក៏ដោយ។ កំជាប់ពាក្យ គឺជាកិច្ចសន្យារវាងបុរស និងនារី ថានិងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត និងដោយធ្វើពិធីកំជាប់ពាក្យ[1]។ តាមន័យនេះ បុរស និងនារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នាអាចបង្ហាញឆន្ទៈដោយសេរីក្នុងការបង្កើតកំជាប់ពាក្យ ហើយបើគ្រាន់តែមានសេចក្ដីសន្យា រវាងបុរស និងនារីថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត វាមិនគ្រប់គ្រាន់នៅឡើយទេ។ ដើម្បីឲ្យពិធីកំជាប់ពាក្យមានសុពលភាព វាចាំបាច់ត្រូវតែមានពិធីកំជាប់ពាក្យតាមប្រពៃណី ទំនៀមទម្លាប់ពីបុរាណបន្ថែមទៀត។

### ១.១.២ លក្ខខណ្ឌនៃកំជាប់ពាក្យតាមបែបប្រពៃណី

កំជាប់ពាក្យ ឬពិធីលើកស្លា ជាការនិយាយភាសាដែលប្រជាជនខ្មែរតែងប្រើប្រាស់ប្រចាំថ្ងៃ ហៅថាពិធីភ្ជាប់ពាក្យ។ ពិធីភ្ជាប់ពាក្យ ឬពិធីលើកស្លា ឬពិធីកំជាប់ពាក្យជាប្រពៃណីខ្មែរមានតាំងពីបុរាណ ហើយក៏ជាពិធីធំមួយ មុនឈានដល់ការរៀបអាពាហ៍ពិពាហ៍។ ពិធីបែបប្រពៃណីមួយនេះ ត្រូវបានប្រជានជនខ្មែរអនុវត្តតៗគ្នាតាំងពីបុរាណកាលរហូតមកដល់ពេលបច្ចុប្បនេះ ក្នុងគោលបំណងភ្ជាប់នូវសម្ព័ន្ធភាពរវាងគ្រួសារពីរ មុននឹងឈានដល់ពិធីអាពាហ៍ពិពាហ៍។ យើងសម្គាល់ឃើញថា បុរស និងនារីដែលមានបំណងនឹងរៀបអាពាហ៍ពិពាហ៍តែងតែរៀបចំនូវពិធីកំជាប់ពាក្យនេះឡើងដោយហៅជាសាមញ្ញថា "ពិធីស៊ីដណ្ដឹង" ឬតាមប្រពៃណីហៅថា "ពិធីលើកស្លា" ដែលក្នុងពិធីនេះយើងឃើញថា ភាគីខាងបុរសរៀបចំនូវជំនូន បណ្ណាការជូនទៅខាងនារី ដោយមានការចូលរួមពីឪពុកម្ដាយ ញាតិមិត្ត និងបងប្អូនទាំងសងខាងដើម្បីចូលចែវចូវ។

សព្វថ្ងៃពិធីនេះនៅមានការនិយមធ្វើជាទូទៅ មុននឹងបុត្រធីតារបស់ពួកគេឈានទៅដល់ថ្ងៃអាពាហ៍ពិពាហ៍ ហើយនៅក្នុងគ្រួសារដែលមានជីវភាពធូរធាបានរៀបចំពិធីនេះយ៉ាងអធិកអធមប៉ុនគ្នានឹងអាពាហ៍ពិពាហ៍ដែរ។ ប៉ុន្តែសម្រាប់ប្រជាជនដែលមានជីវភាពក្រក្សត់ បានលើកពិធីនេះចោលក៏មានដែរ។ ពិធីនេះច្រើនធ្វើរយៈពេលមួយព្រឹក ឬមួយថ្ងៃពេញតែម្ដង ហើយមានការបំពាក់ចិញ្ចៀន ឬខ្សែក ឬប្រគល់វត្ថុអនុស្សាវរីយ៍ផ្សេងៗដល់អនាគតគូស្វាមី ភរិយាថ្មី តាមការនិយម និងធនធានដែលភាគីមាន។

[1] មាត្រា៩៤៨,ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

### ១.១.៣ លក្ខខណ្ឌតាមផ្លូវច្បាប់នៃកំជាប់ពាក្យ

នៅក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ត្រង់គន្លឹះទី៧ ជំពូក២ បានទទួលស្គាល់ពិធីនេះជាផ្លូវការ និងជាវិធាន ដែលកំណត់ឲ្យភាគីត្រូវធ្វើការសម្រេចចិត្តដោយសេរីចេញពីឆន្ទៈនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ដោយហេតុថាក្នុងករណីខ្លះកំជាប់ពាក្យនេះត្រូវបានធ្វើឡើងដោយមិនគោរពឆន្ទៈរបស់ភាគីទេ ប៉ុន្តែបែរជាសម្រេចទៅតាមឆន្ទៈរបស់ឪពុកម្ដាយទៅវិញ។ កំជាប់ពាក្យនេះ គឺជាពិធីមួយដែលភាគីបុរស និងនារីដែលឈានដល់វ័យគ្រប់អាយុរៀបអាពាហ៍ពិពាហ៍បានសន្យានឹងគ្នាថា នឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត ហើយមានចាស់ទុំទាំងសងខាង អ្នកផ្លូវចៅមហា ភ្ញៀវកត្តិយសជាសាក្សី និងដឹងឮផងដែរ។ ដូចនេះក្រមរដ្ឋប្បវេណីកំណត់ថា កំជាប់ពាក្យត្រូវធ្វើឡើងដោយឆន្ទៈសេរីរបស់ភាគី។ កំជាប់ពាក្យនេះត្រូវទុកជាបានការ លុះត្រាតែភាគីបានធ្វើពិធីនេះជាឱឡារិកដែលហៅថា ពិធីលើកស្លា។

### ១.១.៤ ការមិនកំណត់អាយុនៃពិធីកំជាប់ពាក្យ

ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនបានកំណត់លក្ខខណ្ឌអាយុ សម្រាប់ពិធីកំជាប់ពាក្យ នេះដូចកាលកំណត់ការរៀបអាពាហ៍ពិពាហ៍នោះទេ ពោលគឺពិធីកំជាប់ពាក្យមិនទាន់ដល់ពេល កំណត់ឲ្យភាគីអាចរស់នៅជាមួយគ្នាជាប្ដីប្រពន្ធបានឡើយ ពិធីនេះអាចទុករយៈពេលវែងដើម្បីរៀបអាពាហ៍ពិពាហ៍។ ជាក់ស្ដែងណាស់ភាគីដែលបានធ្វើពិធីកំជាប់ពាក្យហើយគេអាចរក្សាទុករយៈពេលវែងដើម្បីរៀបអាពាហ៍ពិពាហ៍ អាស្រ័យដោយការចាំបាច់របស់ភាគី ដូចជាការសិក្សា មិនទាន់ដល់អាយុរៀបការប៉ុន្តែពួកគេស្រលាញ់គ្នាសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅថ្ងៃអនាគត ជៀសសវាងភាគីដ៏ទៃទៀតមកទាក់ទង ឬមិនទុកចិត្តគ្នា ឬខ្លាចការផ្លាស់ប្ដូរចិត្ត។

ជាការពិតណាស់ ចៅមហាខាងប្រុសតែងតែ សួរមករកមេបាខាងស្រីថា តើលោកមេបាយល់ព្រមដែរឬអត់? ប្រសិនបើលោកមេបាខាងស្រីព្រមហើយ ទើបពិធីនេះបានប្រព្រឹតទៅដល់ចប់។

## ១.២ ករណីរំលាយពិធីកំជាប់ពាក្យ

### ១.២.១ ការរំលាយពិធីកំជាប់ពាក្យ

តាមន័យច្បាប់ កំជាប់ពាក្យត្រូវបានបង្កើតឡើងតាមការសន្យារវាងបុរស និងនារីថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាថ្ងៃអនាគត ដោយធ្វើពិធីកំជាប់ពាក្យ។ កំជាប់ពាក្យត្រូវបានគោរពយ៉ាងតឹងរឹងនូវ ឆន្ទៈរបស់ជនដែលពាក់ព័ន្ធ គឺបុរស និងនារីមិនមែនគោរពលើឆន្ទៈរបស់ឪពុកម្ដាយនោះទេ ប៉ុន្តែជាក់ស្ដែងនៅក្នុងសង្គមខ្មែរ កំជាប់ពាក្យត្រូវបានគោរពតាមឆន្ទៈរបស់ឪពុកម្ដាយទៅវិញ។ នៅក្នុងទំនាក់ទំនងនៃកំជាប់ពាក្យយើងសង្កេតឃើញថា មានគូស្រករមួយចំនួនបានសម្រេចបំណងដល់បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយរួមរស់ជាគូស្វាមីភរិយាតទៅ។ ប៉ុន្តែមានករណីមួយចំនួនទៀត បុរសនារីដែលបានប្រារព្ធពិធីកំជាប់ពាក្យហើយ ក៏មិនអាច

សម្រេចបាននូវអាពាហ៍ពិពាហ៍ជាមួយគ្នាផងដែរ ដោយត្រូវរំលាយកំជាប់ពាក្យទៅវិញ។ ក្នុងករណីនេះមានស្ថានភាពជាច្រើនដែលនាំឲ្យគោលបំណងនៃកំជាប់ពាក្យមិនបានសម្រេច ដែលជាហេតុនាំឲ្យកំជាប់ពាក្យត្រូវបានរំលាយដូចជា ការទទួលមរណៈភាពរបស់ភាគីម្ខាងទៀត ការប្រព្រឹត្តកំហុសធ្ងន់ធ្ងរដោយភាគីម្ខាងទៀត ឬដោយការព្រមព្រៀងគ្នា ដែលទាំងនេះសុទ្ធសឹងតែជាមូលហេតុនៃការរំលាយកំជាប់ពាក្យ។

### ១.២.២ ការធ្វើបណ្តឹងទាមទារសំណងនៃការខូចខាតនៃការរំលាយ

ក្នុងករណីដែលកំជាប់ពាក្យត្រូវបានរំលាយ ភាគីដែលបានលើកជំនូននៅពេលកំជាប់ពាក្យដែលសង្ឃឹមថា នឹងបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារឲ្យភាគីម្ខាងទៀតសងជំនូនទាំងនោះមកវិញបាន[2]។ ក្នុងន័យនេះ បើភាគីបុរសជាអ្នកជូនជំនូន នោះភាគីខាងបុរសអាចទាមទារជំនូននោះ ពីភាគីខាងនារីវិញបាន។ ក៏ប៉ុន្តែក្នុងករណីដែលភាគីម្ខាងបានធ្វើការរំលាយកំជាប់ពាក្យចោលដោយមូលហេតុមិនត្រឹមត្រូវ ឬមិនសមស្របភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតបាន[3]។ ជាឧទាហរណ៍៖ កំជាប់ពាក្យត្រូវបានបង្កើតឡើងរួចហើយ ហើយភាគីម្ខាងបានប្រកាសរំលាយកំជាប់ពាក្យនោះដោយគ្មានមូលហេតុត្រឹមត្រូវនោះភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតបាន ដែលការទាមទារសំណងនេះ អាចឈរលើមូលដ្ឋាននៃការមិនអនុវត្តន៍កាតព្វកិច្ច ឬអំពើអនីត្យានុកូល ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។

ចំពោះសំណងនៃការខូចខាតដែលត្រូវទាមទារ អាចរាប់បញ្ចូលទាំងសំណងខាងផ្លូវចិត្ត សម្ភារៈ និងសេដ្ឋកិច្ច ដែលក្រៅពីជំនូន មានន័យថា ការសងជំនូនមិនមែនជាផ្នែកមួយនៃសំណងនៃការខូចខាតនោះទេ ព្រោះការទាមទារជំនូនអាចអនុវត្តតែចំពោះភាគីលើកជំនូនដែលជាខាងបុរសតែប៉ុណ្ណោះ។ បានសេចក្តីថា បើភាគីដែលបដិសេធកំជាប់ពាក្យជាភាគីខាងបុរសវិញ នោះខាងនារីមិនអាចទាមទារឲ្យសងជំនូនបានឡើយ ដោយហេតុថា ជំនូនត្រូវបានភាគីខាងនារីទទួលបានហើយ តែភាគីខាងនារីអាចទាមទារនូវការខូចខាតដូចជាថ្លៃជួលរោង តុ ចុងភៅ សំអាងការ ថ្លៃគ្រឿងអលង្ការ (ចិញ្ចៀនភ្ជាប់ពាក្យ) និងសំណងជំងឺចិត្តជាអាទិ៍។

ផ្ទុយមកវិញ បើកំជាប់ពាក្យត្រូវបានរំលាយដោយសារការព្រមព្រៀង ភាគីអាចកំណត់ពីការទទួលខុសត្រូវរៀងៗខ្លួនបាន ហើយភាគីត្រូវគោរពតាមការព្រមព្រៀងនោះ។ ឧទាហរណ៍ថា ភាគីបុរស និងនារីបានព្រមព្រៀងគ្នារំលាយកំជាប់ពាក្យដោយមិនទាមទារអ្វីពីគ្នាទៅវិញទៅមកឡើយ ដោយខាងបុរសមិនទាមទារជំនូន ហើយខាងនារីមិនទាមទារថ្លៃសោហ៊ុយកំជាប់ពាក្យជាដើម។

[2] មាត្រា៩៤៥,ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[3] មាត្រា៩៤៦, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

### ១.២.៣ អំឡុងពេលធ្វើបណ្តឹងនៃការរំលាយ

ចំពោះការទាមទារឲ្យសងជំនួន និងការទាមទារសំណងខូចខាត ភាគីអាចអនុវត្តសិទ្ធិទាមទារតាមផ្លូវតុលាការ ដោយយោងតាមមាត្រា៩៤៧ នៃក្រមរដ្ឋប្បវេណី។ អំឡុងពេលនៃការដាក់ពាក្យបណ្តឹងទាមទារត្រូវធ្វើឡើងក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីពេលដែលកំដាប់ពាក្យនោះត្រូវបានរលាយ[4]។ ឧទាហរណ៍៖ កំដាប់ពាក្យត្រូវបានរំលាយ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ នោះថេរៈវេលាមួយឆ្នាំ គឺ ត្រឹមថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០២៣ ដូចនេះភាគីអាចដាក់ពាក្យបណ្តឹងក្នុងអំឡុងពេលនេះបាន។ ប៉ុន្តែប្រសិនបើផុតរយៈពេលខាងលើនេះ ភាគីលែងមានសិទ្ធិទាមទារសំណងទៀតឡើយ ។

## ១.៣ លក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍

### ១.៣.១ និយមន័យនៃអាពាហ៍ពិពាហ៍

តាមសទ្ទានុក្រមបា-រាំងខ្មែរ នៃពាក្យច្បាប់ ឆ្នាំ២០០៥ បានផ្តល់និយមន័យ អាពាហ៍ពិពាហ៍ គឺជាសមគ្គសង្វាសស្របច្បាប់របស់នារីម្នាក់ និងបុរសម្នាក់ដែលកើតចេញពីការប្រកាសយ៉ាងឱឡារិក ដើម្បីបង្កើតជាគ្រួសារ។

យោងតាមមាត្រា៣ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦បានចែងថា អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងនារីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញទៅតាមទំនើងចិត្តខ្លួន។ អាពាហ៍ពិពាហ៍នឹងមានអនុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះ ធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ។

### ១.៣.២ លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍

ជាគោលការណ៍ អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន វាអាស្រ័យលើកត្តាជាច្រើនដែលច្បាប់តម្រូវដែលក្នុងនោះ យើងឃើញថាច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២000 និងបទបញ្ញត្តិផ្សេងៗទៀតបានចង្អុលបង្ហាញយ៉ាងច្បាស់លាស់អំពីលក្ខខណ្ឌតម្រូវទាំងនោះ។ ហេតុដូច្នេះ អាពាហ៍ពិពាហ៍អាចនឹងមានអនុភាពពេញលេញបានលុះត្រាតែអាពាហ៍ពិពាហ៍នោះគោរពលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

លក្ខខណ្ឌគ្រឹះ គឺជាធាតុសំខាន់បំផុតដើម្បីបង្កើតអាពាហ៍ពិពាហ៍ ក្នុងករណីនេះបុគ្គលដែលមានបំណងចង់បង្កើតអាពាហ៍ពិពាហ៍នឹងគ្នានេះ ត្រូវបំពេញឲ្យជាដាច់ខាត។ ក្នុងលក្ខខណ្ឌគ្រឹះរួមមាន៖

- លក្ខខណ្ឌភេទរបស់ភាគី។

[4] មាត្រា៩៤៧,ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

- លក្ខខណ្ឌអាយុ។
- គោលការណ៍ស្ម័គ្រចិត្ត។
- ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន។
- ការរៀបអាពាហ៍ពិពាហ៍ជននៅក្រោមអាណាព្យាបាលទូទៅ។
- លក្ខខណ្ឌទាក់ទងនឹងការហាមឃាត់ការរៀបអាពាពិពាហ៍។

ចំណែកឯលក្ខខណ្ឌទម្រង់នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរតាមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា គឺអនុលោមតាមាត្រា៩៥៥ ដល់មាត្រា៩៥៧ នៃក្រមរដ្ឋប្បវេណី ច្បាប់ពីអាពាហ៍ពិពាហ៍ និងគ្រួសារ អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០។ ដោយឡែកមាត្រា៩៥៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ ដោយបានចែង៥ចំណុចដូចខាងក្រោមនេះ៖

- ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។
- ការជូនដំណឹងជាសាធារណៈ។
- បណ្តឹងទាស់មិនឲ្យរៀបអាពាហ៍ពិពាហ៍។
- ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍។
- ការចេញសំបុត្រអាពាហ៍ពិពាហ៍។

### ១.៣.៣ លក្ខខណ្ឌនៃអាយុនៃភាគី

ជាគោលការណ៍ បុរស និងនារីដែលចង់រៀបអាពាហ៍ណិពាហ៍ត្រូវតែមានអាយុពេញលេញ ដែលកំណត់ដោយច្បាប់ ប៉ុន្តែមានករណីពិសេសមួយចំនួនដែលត្រូវបានបញ្ញត្តិច្បាប់។ មាត្រា៥ នៃច្បាប់អាពាហ៍ពិពាហ៍ ឆ្នាំ១៩៨៩ តម្រូវឲ្យបុរសមានអាយុ២០ឆ្នាំ និងនារីមានអាយុយ៉ាងតិច១៨ឆ្នាំ។ ក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់២០ឆ្នាំ និងនារីមិនទាន់ដល់អាយុ១៨ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បានស្របច្បាប់ ប្រសិនបើខាងនារីមានផ្ទៃពោះ ហើយមាតាបិតា ឬអាណាព្យាបាល ដើរតួសំខាន់ក្នុងការសម្រេច។

យោងមាត្រា៩៤៨ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តិថា ករណីដែលបានលើកឡើងខាងលើពីអាយុគ្រប់លក្ខណៈសម្រាប់រៀបអាពាហ៍ពីពាហ៍នោះថា បុរស និងនារីដែលមិនទាន់ដលនីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែក្នុងករណីភាគីម្ខាងទៀតដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជន មិនក្រោម១៦ឆ្នាំ អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអា

ណាព្យាបាលរបស់អនីតិជននោះ[5]។ ប្រសិនមិនមានការយល់ព្រមពីអំណាចមេបាម្ខាង គ្រាន់តែមានមេបាតែម្ខាងទៀតយល់ព្រម ជាការគ្រប់គ្រាន់ហើយ។

ក្នុងករណីអ្នកមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជន មិនព្រមដោយគ្មានមូលហេតុត្រឹមត្រូវសមរម្យ អនីតិជនដែលមានបំណងរៀបអាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឲ្យសម្រេចជំនួសការយល់ព្រមនោះបាន។

### ១.៣.៤ ការកំណត់ភេទនៃភាគី

ច្បាប់បានកំណត់អំពីអាពាហ៍ពិពាហ៍ស្របច្បាប់ដែលត្រូវធ្វើឡើងរវាងមនុស្សមានភេទផ្ទុយគ្នា។ យោងមាត្រា៤៥ កថាខណ្ឌទី៣ និង៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ និងមាត្រា២ នៃច្បាប់ឯកពន្ធភាព ឆ្នាំ២០០៦ បានកំណត់អំពីភេទភាគី ដែលអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន ត្រូវតែជាបុរស និងនារី។ ចំណែកមាត្រា៩៤៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងថាបុរស និងនារីដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។

### ១.៣.៥ គោលការណ៍ស្ម័គ្រចិត្តនៃភាគី

បុរស និងនារីដែលបានសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្តដោយគ្មានការបង្ខិតបង្ខំពីឪពុកម្តាយ ឬអាណាព្យាបាល។ ភាគីមួយមិនអាចបង្ខំភាគមួយទៀតឲ្យរៀបអាពាហ៍ពិពាហ៍ដែលផ្ទុយនឹងឆន្ទៈគេឡើយ ហើយតតិយជនក៏មិនអាចបង្ខំភាគីណាមួយឲ្យរៀបអាពាហ៍ពិពាហ៍ដែលផ្ទុយនឹងឆន្ទៈរបស់ពួកគេ។ អាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំត្រូវបានហាមឃាត់។

គោលការណ៍ស្ម័គ្រចិត្ត ដើម្បីរៀបអាពាហ៍ពិពាហ៍នេះត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ដែលជាច្បាប់កំពូលប្រទេសត្រង់មាត្រា៤៥ កថាខណ្ឌទី៤ បានចែងថា អាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ។

មាត្រា៩៥៨ ចំណុច ក នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧បានកំណត់ថាមោឃភាពនៃអាពាហ៍ពិពាហ៍ប្រសិនសិនបើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ រវាងភាគីដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និងមូលហេតុផ្សេងៗទៀត។

## ១.៤ អាពាហ៍ពិពាហ៍របស់ជនត្រូវបានកម្រិតសមត្ថភាព

### ១.៤.១ ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន

អនីតិជន សំដៅលើជនដែលមានអាយុក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ[6]។

---

[5] មាត្រា៩៤៨,ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[6] មាត្រា១៧, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

បុរស និងនារីដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ[7]។ បើយោងតាមមាត្រា៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារតម្រូវឲ្យបុរសមានអាយុយ៉ាងតិច ២០ឆ្នាំ និងនារីមានអាយុយ៉ាងតិច ១៨ឆ្នាំ។ ប៉ុន្តែទោះបីជាបុរសមិនទាន់ដល់អាយុ ២០ឆ្នាំហើយនារីមិនទាន់ដល់អាយុ ១៨ ឆ្នាំក៏ដោយ ក្នុងករណីដែលនារីមានផ្ទៃពោះ បុរស និងនារីនោះអាចរៀបអាពាហ៍ពិពាហ៍បាន ដោយមានការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល។ ចំណែកឯក្រមរដ្ឋប្បវេណីចាស់ ត្រង់មាត្រា ១៦៦ បានកំណត់អាយុអប្បបរមាសម្រាប់រៀបអាពាហ៍ពិពាហ៍ ១៧ ឆ្នាំសម្រាប់បុរស និង១៤ ឆ្នាំសម្រាប់នារី។ អាពាហ៍ពិពាហ៍គឺជាស័ម្ពន្ធភាពមួយជីវិតរវាងបុរស និងនារី ដូច្នេះបុរស និងនារីចាំបាច់ត្រូវបានពេញវ័យទាំងផ្នែកសេដ្ឋកិច្ច សង្គម ផ្លូវចិត្ត និងផ្លូវកាយ។

ប៉ុន្តែទោះបីជាច្បាប់បានកំណត់ថា អាយុ១៨ឆ្នាំគឺជាអាយុនីតិភាព និងជាអាយុដែលសមរម្យអាចរៀបអាពាហ៍ពិពាហ៍បាន ប៉ុន្តែដោយសារនៅតាមជនបទ មានអាពាហ៍ពិពាហ៍របស់អនីតិជនជាច្រើន ទើបច្បាប់កម្ពុជា ក៏ដូចជាមាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីបច្ចុប្បន្ន តម្រូវឲ្យមានការយល់របស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលដើម្បីបំពេញបន្ថែមលើការខ្វះខាតនូវសមត្ថភាពយល់ព្រមរបស់អនីតិជនដើម្បីរៀបអាពាហ៍ពិពាហ៍បាន។ ករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយអនីតិជន អនីតិជននោះចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជននោះ[8]។

បើអ្នកមានអំណាចមេបាណាម្ខាងមិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្ខាងទៀតជាការគ្រប់គ្រាន់ហើយ[9]។

ក្នុងករណីដែលអ្នកមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជនបដិសេធការយល់ព្រមដោយគ្មានមូលហេតុសមរម្យ អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឲ្យសម្រេចសេចក្តីជំនួសការយល់ព្រមនោះបាន។

### ១.៤.២ ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ(ជនវិកលចរិក)

#### ក. ជននៅក្រោមអាណាព្យាបាលទូទៅ

[7] មាត្រា៩៤៨, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[8] មាត្រា៩៥៣, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[9] មាត្រា៩៥៣, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យ ដោយសារតែមានវិបត្តិផ្នែកបញ្ញាស្មារតី រួមមាន៖

- ជនដែលមិនអាចទៅទៅអីវ៉ាន់ប្រចាំថ្ងៃខ្លួនឯកឰងបាន ហើយចាំបាច់ត្រូវមានអ្នកណាធ្វើជំនួយ។
- ជនដែលមិនដឹងអ្វីៗដែលកើតមានឡើងជារៀងរាល់រាល់ថ្ងៃ ( ឈ្មោះ គ្រួសារ ទីកន្លែងដែលខ្លួនរស់នៅជាដើម)។
- ជនដែលធ្លាក់ក្នុងស្ថានភាពជាមនុស្សរុក្ខជាតិ(អាចជាស្ថានភាពស្លាប់ខួរក្បាល)។

ចំពោះជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង៤(បួន)ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ[10]។

### ខ. ករណីលើកលែងដែលអាចរៀបអាពាហ៍ពិពាហ៍បានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ អាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអប្បបរិមា ដែលចាំបាច់រៀបអាពាហ៍ពិពាហ៍។ ក្នុងករណីនេះ មិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ[11]។ ទោះបីបុគ្គលម្នាក់ជានីតិជនដែលមានសមត្ថភាពមិនគ្រប់គ្រាន់ក្នុងការធ្វើការវិនិច្ឆ័យក៏ដោយ ឲ្យតែមានសមត្ថភាពដែលបង្ហាញឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍បាន ការសម្រេចចិត្តផ្ទាល់របស់បុគ្គលនោះ ត្រូវបានគោរពហើយអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ។

## ១.៤.៣ ការរៀបអាពាហ៍ពិពាហ៍របស់បុគ្គលដែលទទួលបានអត្តាធីនភាព

### ក. អត្ថន័យអត្តាធីនភាព

**អត្តាធីនភាព៖** ជាស្ថានភាពមួយដែលផ្ដល់ឲ្យអនីតិជនបានរួចផុត ពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ[12]។ អនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវបានចាត់ទុកថាបានដល់នីតិភាព[13]។

---

[10] មាត្រា២៤, កថាខណ្ឌទី១ វាក្យខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[11] មាត្រា៩៥៤, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[12] សន្ទានុក្រមផ្នែករដ្ឋប្បវេណី។

[13] មាត្រា២២, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

### ខ. លក្ខខណ្ឌទទួលបានអត្តាធីនភាព

នៅក្នុងករណីដែលអនីតិជនបានដល់អាយុ១៦ (ដប់ប្រាំមួយ) ឆ្នាំទ្រទ្រង់ជីវភាពខ្លួនឯងបានដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបានតាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពនោះស្របនឹងផលប្រយោជន៍របស់អនីតិជននោះ[14]។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា[15]។

អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានពាក្យប្រកាសពីតុលាការនោះទេ[16]។ ជាគោលការណ៍ ទាំងបុរស និងស្ត្រីបើមិនមានអាយុគ្រប់១៨ឆ្នាំ មិនអាចរៀបអាពាហ៍ពិពាហ៍បានទេ ប៉ុន្តែឲ្យតែមានអាយុគ្រប់១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ពីព្រោះថាអនីតិជនដែលមានគំនិតចាស់ទុំអាចរៀបអាពាហ៍ពិពាហ៍នេះ អាចចាត់ទុកជានីតិជនដែលអាចប្រកិច្ចការជួយដូរបាន ដូច្នេះត្រូវផ្តល់អត្តាធីនភាពដល់អនីតិជននោះ ដើម្បីធានានូវឯករាជ្យភាពនៃអាពាហ៍ពិពាហ៍។

នៅក្នុងករណីដែលអនីតិជន ដែលទទួលបានអត្តាធីនភាព នោះអានុភាពនៃអត្តាធីនភាពនោះបានផ្តល់សិទ្ធិ និងកណីកិច្ចឲ្យអនីតិជននោះមានសិទ្ធិដូចគ្នាទៅនឹងនីតិជនដែរ។ ប្រសិនបើអនីតិជននោះមានបំណងរៀបអាពាហ៍ពិពាហ៍ មិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយដូចជាអនីតិជនធម្មតានោះទេ។ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងគោរពគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ[17]។ គឺមានន័យថាគោលការណ៍នៃអាពាហ៍ពិពាហ៍ត្រូវគោរពតាមច្បាប់ ហើយយកតាមការព្រមព្រៀងរបស់គូភាគីនៃអាពាហ៍ពិពាហ៍ដោយមិនមានការជ្រៀតជ្រែក ឬអន្តរាគមន៍ពីតតិយនោះទេ ។

## ១.៥ ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍

### ១.៥.១ ការហាមឃាត់មិនឲ្យមានទ្វេពន្ធភាព

បុគ្គលដែលមានប្តី ឬប្រពន្ធហើយ ចំណងអាពាហ៍ពិពាហ៍នោះនៅមានសុពលភាពនៅឡើយ (មិនទាន់លែងលះគ្នា) ហើយចង់រៀបអាពាហ៍ពិពាហ៍ប្តី ឬប្រពន្ធថ្មីមួយទៀតគឺមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ[18]។ ជាក់ស្តែងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា៤៥ ដែលមានគោលបំណងសំខាន់ក្នុងការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ។ មាត្រានេះចែងថា

[14] មាត្រ ២១, កថាខណ្ឌទី១, វាយក្យខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។
[15] មាត្រា២១, កថាខណ្ឌទី១, វាយក្យខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។
[16] មាត្រា២១, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។
[17] មាត្រា៤៥, កថាខណ្ឌទី៤, រដ្ឋធម្មនុញ្ញ, ២៤ កញ្ញា ១៩៩៣។
[18] មាត្រា១៩, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាលើគ្រប់វិស័យជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។ អាពាហ៍ពិពាហ៍ត្រូវធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ។

ចំណែកនៅក្នុងក្រមចាស់ ត្រង់មាត្រា១៣៩ អនុញ្ញាតឲ្យបុរសអាចរៀបអាពាហ៍ពិពាហ៍លើកទី១ហើយអាចបន្តរៀបអាពាហ៍ពិពាហ៍លើកទី២បាន ដោយមិនខុសច្បាប់ឡើយ(របបប្តីអាចមានប្រពន្ធច្រើននាក់) និងមាត្រា១៤០ នៃក្រមចាស់ដដែលគឺអនុញ្ញាតឲ្យស្ត្រីអាចរៀបអាពាហ៍ពិពាហ៍បានតែប្តីមួយប៉ុណ្ណោះ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវគោរពតាមគោលការណ៍ឯកពន្ធភាពដោយស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយដោយមានចុះបញ្ជីអាពាហ៍ពិពាហ៍ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្របទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ[19]។

ឯកពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ ដែលបុរសមានប្រពន្ធតែមួយ ឯស្ត្រីមានប្តីតែមួយ។ ដែលហៅថាជាចំណងអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារឹកមួយដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថារួមសមគ្គសង្វាសជាមួយគ្នាតាមបទបញ្ញត្តិនៃច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួន[20]។

### ១.៥.២ អំឡុងពេលហាមឃាត់របស់ស្ត្រីមិនឲ្យរៀបអាពាហ៍ពិពាហ៍

នៅក្នុងករណីដែលអាពាហ៍ពិពាហ៍មុនត្រូវបានបញ្ចប់ដោយមរណភាព លែងលះ ឬមោឃភាពនៃអាពាហ៍ពិពាហ៍នោះ បុរសម្នាក់អាចរៀបអាពាហ៍ពិពាហ៍ជាថ្មីម្តងទៀតបាន នៅពេលណាក៏បានក្រោយបញ្ចប់អាពាហ៍ពិពាហ៍មុន។ ទោះជាយ៉ាងណាក៏ដោយស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ម្តងទៀត ត្រូវរង់ចាំ១២០ថ្ងៃបន្ទាប់ពីបញ្ចប់អាពាហ៍ពិពាហ៍លើកមុន។ ការកំណត់អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀតត្រូវបានកំណត់សម្រាប់នារី ដើម្បីចៀសវាងការប្រកួតប្រជែងទាក់ទងទៅនឹងការសន្មតបិតុភាពរបស់កូនដែលមានន័យថាតើកូនដែលកើតមកគួរត្រូវសន្មតថាជាកូនរបស់ប្តីមុន ឬប្តីក្រោយ។ ចំពោះករណីដែលនារីមានផ្ទៃពោះមុនពេលរៀបអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោលហើយបានសម្រាលកូននោះ ឬចំពោះករណីដែលមានលិខិតបញ្ជាក់ពីការសន្មតផ្ទៃពោះពីវេជ្ជបណ្ឌិត[21]។

នៅក្នុងករណីដែលអាចជៀសវាងការប្រកួតប្រជែងទាក់ទងនឹងការសន្មតបិតុភាពបាន ការរៀបអាពាហ៍ពិពាហ៍អាចត្រូវបានអនុញ្ញាត ដូច្នេះបញ្ញត្តិដែលស្តីពីអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មី

[19] មាត្រា២, ច្បាប់ស្តីពីឯកពន្ធភាព,លេខ នស/រកម/១០០៦/០២៦,២១ តុលា ២០០៦។

[20] មាត្រា៣,ច្បាប់ស្តីពីឯកពន្ធភាព,លេខ នស/រកម/១០០៦/០២៦,២១ តុលា ២០០៦ ។

[21] មាត្រា៩៥០, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

ទៀត មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគ្មានការប្រកួតប្រជែង ឬគ្មានការភ័ន្តច្រឡំណាមួយទាក់ទងនឹងការសន្មតបិតុភាពកូន។

### ១.៥.៣ ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍នៃញាតិលោហិត

អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុងថ្នាក់ទីបី[22]។ បុរស និងស្ត្រីដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នាមិនត្រូវមានចំណងជាប់ញាតិផ្ទាល់ ឬសាខាញាតិលោហិតរហូតដល់ថ្នាក់ទីបី ទោះបីក្នុងករណីដែលមានការបញ្ចប់ទំនាក់ទំនងរវាងឪពុកម្តាយនឹងកូនបង្កើត ឬការកាត់កាល់រវាងឪពុកម្តាយចិញ្ចឹម និងកូនសុំហើយក៏ដោយ។

ការរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតគ្នាត្រូវបានហាមឃាត់ ដោយសារមូលហេតុនៃសុជាតិវិទ្យា និងមូលហេតុនៃសីលធម៌សង្គម។ ចំពោះមូលហេតុសុជាតិវិទ្យា ការរៀបអាពាហ៍ពិពាហ៍រវាងថ្នាក់ញាតិជិតគ្នាងាយនឹងបណ្តាលឲ្យពន្ធុខ្សោយជាប់គ្នា ហើយលទ្ធភាពនៃពិការភាពចំពោះកូនដែលកើតមកកើនឡើងខ្ពស់។ ប៉ុន្តែការហាមឃាត់នូវអាពាហ៍ពិពាហ៍ចំពោះញាតិថ្នាក់ជិតបែបនេះ បណ្តាលមកពីហេតុផលសីលធម៌សង្គមច្រើនជាងសីលធម៌សុជាតិវិទ្យា។ ជាឧទាហរណ៍ ការរៀបអាពាហ៍ពិពាហ៍បែបនេះនឹងបង្កឲ្យមានការរង្កៀសចិត្តគ្នាខាងផ្លូវភេទ ក្នុងចំណោមញាតិថ្នាក់ញាតិជិតទាំងអស់នោះហើយពីទិដ្ឋភាពនៃការចូលរួមក្នុងសង្គម និងបរិយាកាសនៃចិញ្ចឹមបីបាច់កូន ក៏មិនមែនជាការគួរឲ្យប្រាថ្នាហើយក៏នឹងបណ្តាលឲ្យមានផលប៉ះពាល់សុខសាន្តក្នុងគ្រួសារដែរ។ មិនត្រឹមតែប៉ុណ្ណោះ ការរៀបអាពាហ៍ពិពាហ៍រវាងឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម និងកូនសុំក៏ត្រូវបានហាមឃាត់ដែរ។ ទោះបីជាក្នុងទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយបង្កើតត្រូវបានកាត់ផ្តាច់ដោយសារការបង្កើតស្នុំកូនពេញលេញក៏ដោយ ក៏ទំនាក់ទំនងលោហិតតាមធម្មតាមិនរលត់ដែរ ហេតុដូចនេះបានជាការហាមឃាត់ចំពោះអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតនៅតែមានដដែល។

មាត្រា៩៥១ នៃក្រមរដ្ឋប្បវេណីបានហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិដែលមានទំនាក់ទំនងនឹងគ្នា ចំពោះករណីមួយចំនួនដូចខាងក្រោម៖

#### ក. ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់

ញាតិលោហិត សំដៅលើបុគ្គលដែលមានទំនាក់ទំនងសារលោហិតពីកំណើតជាមួយបុគ្គលម្នាក់ទៀត (ញាតិលោកហិតពីកំណើត) ឬបុគ្គលបុគ្គលដែលត្រូវចាត់ទុកដោយច្បាប់ថាមានទំនាក់ទំនងសាច់សារលោហិតជាមួយបុគ្គលជាក់លាក់ម្នាក់ទៀតនោះ(ញាតិលោហិតកំណត់ដោយច្បាប់)។

- រវាងចុងគល់ឬចុងកុលជាមួយចៅចុងកុល(ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៧)

[22] មាត្រា៩៥១, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

- រវាងជីប៉ាជាមួយចៅ(ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៦)
- រវាងជីលាជាមួយចៅលា(ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៥)
- រវាងជីលួតជាមួយចៅលួត(ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៤)
- រវាងជីទួតជាមួយចៅទួត(ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៣)
- រវាងជីតា ឬជីដូនជាមួយចៅ(ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី២)
- រវាងឪពុកម្តាយជាមួយកូន(ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី១)

**ខ.ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងសាខាលោហិត**

សាខាលោហិត គឺសំដៅលើទំនាក់ទំនងញាតិដែលបានបែកចេញពីសាខាបុព្វញាតិតែមួយ។ បុគ្គលទាំងនោះមានដូចជា៖

- រវាងបងប្អូនបង្កើត(សាខាញាតិថ្នាក់ទី២)
- រវាងពូ ឬមីងជាមួយក្មួយ(សាខាញាតិថ្នាក់ទី៣) ។

**គ. ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬម្តាយបង្កើតជាមួយអតីតកូនបង្កើត**

របបសុំកូនពេញលេញមានគោលបំណងចិញ្ចឹមកុមារដែលបានសុំ ឲ្យដូចជាកូនបង្កើតក្នុងមជ្ឈដ្ឋានគ្រួសារដែលមានស្ថិរភាពល្អ ដូច្នេះកូនសុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយចិញ្ចឹម[23]។ ច្បាប់ហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬម្តាយបង្កើតជាមួយអតីតកូនបង្កើតដែលបានបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្តាយបង្កើតដោយសារការបង្កើតសុំកូនពេញលេញ។ មានន័យថាក្នុងករណីដែលអតីតឪពុកបង្កើត ឬអតីតម្តាយបង្កើតត្រូវបានបញ្ចប់នូវភាពជាឪពុក ឬម្តាយបង្កើតដោយសារមូលហេតុណាក៏ដោយ ក៏អតីតឪពុបង្កើត ឬអតីតម្តាយបង្កើតមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយអតីតកូនបង្កើតរបស់ខ្លួនបានដែរ។

**ឃ. ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍អតីតឪពុក ឬម្តាយចិញ្ចឹមជាមួយកូនសុំ**

ច្បាប់ហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមជាមួយកូនសុំ។ ទោះបីជាទំនាក់ទំនងញាតិត្រូវបានកាត់ផ្តាច់ហើយដោយសារមូលហេតុណាក៏ដោយ ក៏អតីតឪពុកម្តាយចិញ្ចឹមមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយអតតីកូនចិញ្ចឹមបានដែរ។

### ១.៥.៤ ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍នៃញាតិពន្ធ

ញាតិពន្ធ សំដៅលើចំណងកតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិតរបស់សហព័ន្ធម្ខាងទៀត ឬហៅថា "សាច់ថ្លៃ"។ ឧទាហរណ៍ឪពុកម្តាយក្មេក និងកូនប្រសារ បងថ្លៃប្អូនថ្លៃខាងប្តី ឬខាងប្រពន្ធ។ ញាតិពន្ធ

[23] មត្រា១០១៤ វាយក្យខណ្ឌទី១ សេចក្តីកំណត់មាត្រាចំពោះនីមួយៗនៃក្រមរដ្ឋប្បវេណី។

ខ្សែផ្ទាល់ សំដៅលើញាតិលោហិតផ្ទាល់ខាងសាច់ថ្លៃដែលកើតពីមួយទៅមួយតាមលំដាប់ ដូចជាជីដូនជីតាក្មេក ឪពុកម្តាយក្មេក កូនបង្កើតរបស់សហព័ន្ធម្ខាងទៀត(ជាកូនចុងរបស់សហព័ន្ធម្ខាងទៀត) ។

បុរស និងស្ត្រីពេលដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នា មិនត្រូវមានជាប់ចំណងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះបីជានៅក្នុងថ្នាក់ណាក៏ដោយ។ អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយរវាងញាតិពន្ធនៃខ្សែផ្ទាល់[24]។ ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធនៃខ្សែផ្ទាល់ និងជនដែលធ្លាប់ជាញាតិពន្ធនៃខ្សែផ្ទាល់ ដោយសាច់ញាតិលោហិតនៃខ្សែផ្ទាល់របស់សហព័ន្ធ មានទំនាក់ទំនងប្រហាក់ប្រហែលនឹងញាតិលោហិតខ្សែផ្ទាល់របស់ខ្លួនផ្ទាល់ ដែលស្រដៀងទៅនឹងទំនាក់ទំនងឪពុកម្តាយ និងកូនដូច្នេះតាមសីលធម៌សង្គមការរៀបអាពាហ៍ពិពាហ៍ក៏មិនមែនជាការគួរដែរ ។

អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងញាតិពន្ធនៅក្នុងថ្នាក់ទីបីថ្នាក់រាប់ទាំងថ្នាក់ទីបីផងដែរ[25]។ ទោះបីជាសាខាញាតិពន្ធក្នុង៣ថ្នាក់ ដោយរាប់ទាំងថ្នាក់ទី៣ផងក៏ដោយ ក៏អាពាហ៍ពិពាហ៍រវាងបុគ្គលទាំងនោះត្រូវបានហាមឃាត់ដែរ ដោយសារតែនៅក្នុងសង្គមកម្ពុជា សាខាញាតិពន្ធនេះមាននិន្នាការបង្កើតទំនាក់ទំនងញាតិជារួមដែលមានលក្ខណៈជិតស្និតស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និងសាខាញាតិលោហិតដែរ។

### ក. ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់

ច្បាប់បានហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ទាំងអស់ ហើយទោះបីជាទំនាក់ទំនងញាតិពន្ធខ្សែផ្ទាល់ត្រូវបានបញ្ចប់ក៏ដោយ។ ខ្សែផ្ទាល់នោះមានដូចជា៖

- រវាងឪពុកម្តាយក្មេក និងកូនប្រសា
- រវាងជីដូនជីតាក្មេក និងចៅប្រសា
- រវាងជីដូនជីតាទួតក្មេក និងចៅទួតប្រសា
- រវាងជីលួតក្មេក និងចៅលួតប្រសា
- រវាជីលាក្មេក និងចៅលាប្រសា
- រវាងអតីតឪពុកម្តាយក្មេក និងអតីតកូនប្រសា
- រវាងអតីតជីដូនជីតាក្មេក និងអតីតចៅទួតប្រសា
- រវាងអតីតជីលួតក្មេក និងអតីតចៅលួតប្រសា
- រវាងអតីតជីលាក្មេក និងអតីតចៅលាប្រសា

[24] មាត្រា៩៥២, កថាខណ្ឌទី១ វាយក្យខណ្ឌទី១,ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។
[25] មាត្រា៩៥២ កថាខណ្ឌទី២ វាយក្យខណ្ឌទី១,ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

ដូចគ្នាផងដែរ ក្រមរដ្ឋប្បវេណីសង្គមចាស់ក៏បានហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតខ្សែផ្ទាល់គ្រប់ថ្នាក់ និងញាតិពន្ធខ្សែផ្ទាល់គ្រប់ថ្នាក់ផងដែរ ដោយបញ្ញត្តិត្រង់មាត្រា១១៨ នៃក្រមរដ្ឋប្បវេណីនៃសង្គមចាស់ចែងថា ច្បាប់បានហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬញាតិពន្ធនឹងគ្នាក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ទោះបីជាចំណងមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬសាច់ចិញ្ចឹមក្តី។

**ខ. ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ**

- រវាងបងថ្លៃប្អូនថ្លៃ(សាខាញាតិពន្ធថ្នាក់ទី២)
- រវាងអតីតបងថ្លៃ និងអតីតប្អូនថ្លៃ
- រវាងពូមីងក្មេកជាមួយក្មួយប្រសា (សាខាញាតិពន្ធថ្នាក់ទី៣)
- រវាងអតីតពូមីងក្មេកជាមួយនឹងអតីតក្មួយប្រសា
- រវាងបងប្អូនបង្កើតរបស់ប្តីជាមួយបងប្អូនបង្កើតរបស់ប្រពន្ធ
- រវាងអតីតបងប្អូនបង្កើតរបស់ប្តីជាមួយអតីតបងបង្អូនបង្កើតរបស់ប្រពន្ធ។

**គ. ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពីពាហ៍រវាងឪពុកម្តាយចុងជាមួយកូនចុង**

ចំពោះករណីឪពុក ឬម្តាយចុងជាមួយកូនចុង ច្បាប់បានហាមឃាត់មិនអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានទេ ក៏ព្រោះទំនាក់ទំនងរវាងឪពុក ឬម្តាយចុងជាមួយកូនចុងស្ថិតនៅក្នុងញាតិពន្ធខ្សែផ្ទាល់។

**ឃ. ករណីលើកលែងអាចរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ**

ចំពោះករណីលើកលែងបែបនេះ ក៏ដោយសារតែតាមទំនៀមទម្លាប់ក្នុងប្រទេសកម្ពុជា មានករណីអាពាហ៍ពិពាហ៍ជាមួយបងប្អូនថ្លៃដូចជាករណីដែលប្តីបានទទួលមរណភាពទៅ ហើយប្រពន្ធបានទៅរៀបអាពាហ៍ពិពាហ៍ជាមួយបង ឬប្អូនប្រុសដែលនៅលីវរបស់សពប្តី ឬក្នុងករណីដែលប្រពន្ធបានទទួលមរណភាព ហើយប្អូនស្រី ឬបងស្រីរបស់សពប្រពន្ធទៅរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ដើម្បីមើលថែកូនរបស់បុគ្គលដែលបានទទួលមរណភាពនោះជាដើម។

# ជំពូកទី២៖ នីតិវិធីនៃការបង្កើតអាពាហ៍ពិពាហ៍

# ជំពូកទី២៖ នីតិវិធីនៃការបង្កើតអាពាហ៍ពិពាហ៍

## ២.១ លក្ខខណ្ឌទម្រង់អាពាហ៍ពិពាហ៍

### ២.១.១ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

បុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអនុត្រនុកូលដ្ឋាន នៃឃុំសង្កាត់ នៃលំនៅឋានសាមីខ្លួនខាងនារី។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យឲ្យបានហ្មត់ចត់នូវពាក្យសុំនោះដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា[26]។ អាពាហ៍ពិបពាហ៍នឹងមានអានុភាពដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចំបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន[27]។

មុនពិធីរៀបអាពាហ៍ពិពាហ៍បុរស និងស្ត្រីដែលមានបំណងរៀបអាពាហ៍ពីពាហ៍នឹងគ្នា ត្រូវធ្វើលិខិតបញ្ជាក់ពីឃុំសង្កាត់ខាងលំនៅឋានរបស់ភាគីរៀងៗខ្លួនអំពីភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយដោយមិនមានការជាប់ជំពាក់ជាមួយមួយបុគ្គលណាផ្សេងឡើយ។ ក្រោយពីបានទទួលកិខិតបញ្ជាក់នេះហើយ ដោយមានទាំងឪពុកម្តាយនៅរស់ ឬអាណាព្យាបាលរួជាមួយផងត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅខាងឃុំ ឬសង្កាត់ភាគីស្ត្រីរស់នៅ។ ក្រោយពីមេឃុំ ឬចៅសង្កាត់ទទួលពាក្យស្នើសុំនោះហើយក្នុងឋានៈលោកជាមន្ត្រីអត្រានុកូលដ្ឋានត្រូវចេញលិខិតអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ និងចេញប័ណ្ណប្រកាសសម្រាប់ការរៀបអាពាហ៍ពិពាហ៍ឲ្យទៅភាគីទាំងពីរយកទៅបិទផ្សាយជាសាធារណៈ។ ការចេញលិខិតបញ្ជាក់ភាពណៅលីវ ឬមេម៉ាយ ឬពោះម៉ាយត្រូវបិទរូបថតទំហំ៤គុណ៦មួយសន្លឹក ហើយលិខិតនោះមានអានុភាពតត្រឹមរយៈពេល៣ខែ។

### ២.១.២ បណ្ណប្រកាសជាសាធារណៈ

នៅពេលទទួលបានពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិឲ្យឲ្យបានហ្មត់ចត់ចំពោះបុរស នារីដែលបានដាក់ពាក្យពាក្យសុំនោះ៖

➢ បើពិនិត្យទៅឃើញថា មិនមានលក្ខណៈត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃក្រមរដ្ឋប្បវេណី និងបញ្ញត្តិនៃអត្រានុកូលដ្ឋានទេ មន្ត្រីអត្រានុកូលដ្ឋានមិនអាចអនុញ្ញាតឲ្យបុរសនារីនោះរៀបអាពាហ៍ពិពាហ៍បានឡើយ។

➢ បើពិនិត្យទៅឃើញថាមានលក្ខណៈត្រឹមត្រូវតាមលក្ខខ័ណ្ឌនៃក្រមរដ្ឋប្បវេណីនិងបទបញ្ញាតនៃអាត្រានុកូលដ្ឋានហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ជាសាធារណៈចំនួន០៥ច្បាប់ដូចជា៖

- ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅលំនៅឋានសាមីខ្លួននារី។

[26] មាត្រា២៨, អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន,លេខ១០៣ អនក្រ កប, ២៩ ធ្នូ ២០០០។

[27] មាត្រា៩៥៥, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

- ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី។
- ០១ច្បាប់រក្សាទុកជាឯកសារនៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី។
- ០២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានខាងបុរស ដើម្បីយកទៅបិទផ្សាយជាសាធារណៈនៅលំនៅឋានសាមីខ្លួនបុរស០១ច្បាប់ នៅសាលាឃុំ ឬសង្កាត់សាមីខ្លួនបុរស០១ច្បាប់។

### ២.១.៣ រយៈពេលនៃការរងចាំ

បណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬថ្ងៃចុះបញ្ជីអាពាហ៍ពិពាហ៍ដើម្បីឲ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនោះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន។ ក្នុងរយៈពេល១០ថ្ងៃអាពាហ៍ពិពាហ៍អាចធ្វើទៅបានបើគ្មានការប្តឹងជំទាស់។ បើមានបណ្តឹងទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បានលុះត្រាតែបណ្តឹងទាស់ត្រូវបានដោះស្រាយរួចរាល់តាមគោលការណ៍ដែលបានចែងងនៅក្នុងក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាន។

មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលមានខ្លឹមសារដូចខាងក្រោម៖

- នាមត្រកូល និងនាមខ្លួន សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ និងទីលំនៅឋានបច្ចុប្បន្ននៃអនាគតប្រពន្ធ។
- នាមត្រកូល និងនាមខ្លួន ថ្ងៃខែឆ្នាំកំណើត មុខរបរ និទីលំនៅបច្ចុប្បន្នរបស់ឪពុកម្តាយ នៃអនាគតប្តីប្រពន្ធ(បើឪពុកម្តាយហស្លាប់ ត្រូវដាក់ថាស្លាប់)។

### ២.១.៤ បុគ្គលដែលអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍

ប្រសិនបើមានជនណាម្នាក់បានដាក់ពាក្យបណ្តឹងជំទាស់ទៅនឹងគម្រោងរៀបអាពាហ៍ពិពាហ៍មន្ត្រីនៃស្ថានប័នពាក់ព័ន្ធត្រូវដោះស្រាយបណ្តឹងនោះឲ្យចប់សព្វគ្រប់សិនទើប ទើបអាចរៀបអាពាហ៍ពិពាហ៍បាន។ បើយោងតាមអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានត្រង់មាត្រា ៣០ កថាខណ្ឌទី២ វាយក្យខណ្ឌទី១ ចែងថា៖ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល១០ថ្ងៃមុរៀបអាពាហ៍ពិពាហ៍ ដើម្បីឲ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមិនមានការយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ។ ប៉ុន្តែអនុក្រឹត្យនេះបានកំណត់ច្បាស់លាស់ទេថាអ្នកណាជាអ្នកមានសិទ្ធិប្តឹងជំទាស់បាននោះទេ ដូច្នេះអ្នកដែលមានសិទ្ធិដែលប្តឹងជំទាស់នោះអាចជាសាច់ញាតិ ឪពុកម្តាយឬអាណាព្យាបាល ឬតតិយជនណាម្នាក់ដែលមានការពាក់ព័ន្ធជាមួយអាពាហ៍ពិពាហ៍ដោយផ្ទាល់ ដូចជាភាគីដែលគ្រោងនឹងរៀបអាពាហ៍ពិពាហ៍ធ្លាប់ជាប្តីប្រពន្ធខ្លួន ហើយមកលួចរៀបអាពាហ៍ពិពាហ៍ជាថ្មី ឬធ្លាប់រស់នៅជាមួយគ្នាពីមុនដោយមិនបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់(មិនបានចុះសំបុត្រអាពាហ៍ពិបាហ៍) អាចប្តឹងជំទាស់គម្រោងរៀបអាពាហ៍ពិពាហ៍ក្នុងចន្លោះ១០ថ្ងៃចាប់ពីថ្ងៃបិទប័ណ្ណប្រកាសអំពីអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងរៀបចំនេះ។

### ២.១.៥ មូលហេតុនៃការថ្លឹងជំទាស់នៃអាពាហ៍ពិពាហ៍

ក្រមរដ្ឋប្បវេណី មាត្រា៩៥៦ បានកំណត់អំពីខ្លឹមសារដែលផ្តល់អំណាចដល់មន្ត្រីអត្រានុកូលដ្ឋាន មានសិទ្ធិបដិសេធមិនទទួលយកសំណើរសុំរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីមានមូលហេតុណាមួយដូចខាងក្រោម៖

- អនាគតប្តី ឬប្រពន្ធមិនទាន់ដល់នីតិភាព(អាយុក្រោម១៨ឆ្នាំ) ឬក្នុងករណីដែលភាគីបានដល់នីតិភាព ហើយភាគីម្ខាងទទៀតមានអាយុក្រោម១៦ឆ្នាំ។
- ករណីភាគីមានសហព័ទ្ធហើយ។
- អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀតក្នុងរណីដែលនារីត្រូវបានរំលាយឬលុបចោលអាពាហ៍ពិពាហ៍មុន ហើយនៅមិនទានគ្រប់រយៈពេល១២ថ្ងៃ។
- ករណីដែលអាពាហ៍ពិពាហ៍បានធ្វើឡើងរវាងញាតិលោហិតរហូតដល់ថ្នាក់ទី៣ និងរាប់ទាំងថ្នាក់ទី៣ផង។
- ករណីដែលអាពាហ៍ពិពាហ៍គ្រោងធ្វើឡើងរវាងសាខាពន្ធនៃខ្សែផ្ទាល់ ឬអាពាហ៍ពិពាហ៍គ្រោងធ្វើឡើងរវាងសាខាញាតិពន្ធរហូតថ្នាក់ទី៣និងរាប់ទាំងថ្នាក់ទីផង។
- អាពាហ៍របស់អានីតិជនដែលមិនមានការយល់ព្រមពីអ្នកមានអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជន។
- អាពាហ៍ពិពាហ៍របស់ជនវិកលចរិក(ជននៅក្រោមអាព្យាបាលទូទៅ) ដែលមិនមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមាបាន។

## ២.២ ការចុះសុំបុត្រអាពាហ៍ពិពាហ៍

### ២.២.១ អំពីមន្ត្រីទទួលបន្ទុក

មេឃុំ ឬចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនដីឃុំ ឬសង្កាត់ដែលខ្លួនគ្រប់គ្រង់។ នៅពេលដែលមេឃុំ ឬចៅសង្កាត់អវត្តមានត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរឲ្យជំទប់ ឬចៅសង្កាត់រង តាមឋានុក្រម និងរាយការណ៍ជូនអភិបាលស្រុក ឬខណ្ឌតាមផ្លូវការ។

ក្នុងករណីមេឃុំ ឬចៅសង្កាត់អវត្តមានដោយស្លាប់ ឬដោយបញ្ឈប់ពីមុខតំណែង ក្នុងចន្លោះពេលដែលមិនទាន់មានរៀបចំមេឃុំ ឬចៅសង្កាត់ថ្មី សិទ្ធិជាមន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ជូនទៅជំទប់ ឬចៅសង្កាត់រងតាមឋានានុក្រម។

### ២.២.២ អំពីសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍

**សៀវភៅអត្រានុកូលដ្ឋានទាក់នឹងអាពាហ៍ពិពាហ៍រួមមាន៖**

- សៀវភៅអត្រានុកូលដ្ឋានអាពាពិពាហ៍។
- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្រប់ច្បាប់។
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍។

**ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍រួមមានៈ**

- សំបុត្រអាពាហ៍ពិពាហ៍។
- សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។
- សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

### ២.២.៣ ឯកសារពាក់ព័ន្ធ

បុរស និងនារីដែលមកសុំច្បាប់រៀបអាពាហ៍ពិពាហ៍ ត្រូវភ្ជាប់មកជាមួយនូវៈ

- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត។
- លិខិតបញ្ជាក់ភាព នៅលីវ ឬមេម៉ាយ ឬពោះម៉ាយ របស់សាមីខ្លួនទាំងពីរ។ លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយទាំងពីរនាក់ ត្រូវចេញដោយមេឃុំ ឬចៅសង្កាត់សាមី។ បើក្នុងករណីមេម៉ាយ ឬពោះម៉ាយដោយប្តី ឬប្រពន្ធត្រូវភ្ជាប់មកជាមួយសេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្រមរណភាព។
- សៀវភៅគ្រួសារ ដែលមានទិន្នន័យរបស់សាមីខ្លួនទាំងពីរនាក់ច្បាស់លាស់ និងត្រឹមត្រូវ។

### ២.២.៤ ការចុះបញ្ជីអាពាហ៍ពិពាហ៍

ក្រោយរៀបអាពាហ៍ពិពាហ៍រួចហើយ ដំណាក់ចុងក្រោយក្នុងការបង្កើតឲ្យមានអាពាហ៍ពិពាហ៍ស្រប់ច្បាប់មួយ ដែលទទួលស្គាល់ដោយច្បាប់ គឺការ **ចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន**។

អាពាហ៍ពិពាហ៍ នឹងចាត់ទុកត្រឹមត្រូវតាមលក្ខណៈច្បាប់បានលុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តទទួលគ្នាជាប្តីប្រពន្ធចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅលំនៅឋានរបស់នារី។ កិច្ចសន្យានេះត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអាត្រានុកូលដ្ឋាន និងផ្តិតមេដៃប្តីប្រពន្ធ និងសាក្សីគ្រប់អាយុចំនួន ០២នាក់ផង[28]។

### ២.២.៥ ការចេញ ឬការផ្តល់សំបុត្រអាពាហ៍ពិពាហ៍

នៅពេលសាមីខ្លួន អនាគតប្តី និងប្រពន្ធបានមករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ បន្ទាប់មកប្រគល់ឲ្យសាមីខ្លួនប្តីប្រពន្ធនូវសំបុត្រមួយហៅថា សំបុត្រអាពាហ៍ពិពាហ៍ ជាច្បាប់ដើមមួយច្បាប់ និងសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ មួយចំនួនទៀតតាមការ

[28] មាត្រា៣០, អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន,លេខ១០៣ អនក្រ កប, ២៩ ធ្នូ ២០០០។

ស្នើសុំរបស់ភាគី។ នៅក្នុងសំបុត្រអាពាហ៍ពិពាហ៍ មានចុះឈ្មោះរបស់សហព័ទ្ធ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ថ្ងៃខែឆ្នាំចុះសំបុត្រអាពាហ៍ពិហ៍ និងទីកន្លែងសំបុត្រអាពាហ៍ពិពាហ៍ជាដើម។

## ២.៣ អានុភាពនៃអាពាហ៍ពិពាហ៍

### ២.៣.១ ការប្រើនាមត្រកូលរបស់ប្ដីប្រពន្ធ

ផ្អែកតាមការកំណត់នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធអាចប្រើនាមត្រកូលរបស់ប្តី ឬប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន[29]។ ការគោរពសិទ្ធិស្វ័យសម្រេចចំពោះនាមត្រកូល និងសិទ្ធិបុគ្គល និងជានារបេបដែលប្តីប្រពន្ធអាចជ្រើសរើសប្រើនាមត្រូកូលខុសគ្នា។ ជាគោលការណ៍នៅប្រទេសកម្ពុជា ប្រើនាមត្រកូលខុសគ្នា ដោយសារតែនាមត្រកូលបញ្ជាឲ្យតំណខ្សែលោហិត និងឬសគល់នៃឪពុកម្តាយ និងដូនតា ហើយដោយសារវាមានតួនាទីសម្គាល់អត្តសញ្ញាណរបស់ជនគ្រប់រូបជាមួយនឹងនាមខ្លួន ទើបយើងសម្រេចយកយន្តការដែលជនគ្រប់រូបអាចជ្រើសរើសដោយសេរីនូវនាមត្រកូល បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច។ នៅកម្ពុជាកូនដែលកើតមកតាមទំនៀបទម្លាប់ គឺដាក់ឈ្មោះ ឪពុក ជីតា ឬបុព្វជនដែលចាស់ជាងនេះទៅទៀត ប៉ុន្តែការអនុវត្តយកនាមត្រកូលគ្រួសារពុំច្បាស់លាស់ទេ។ ប៉ុន្តែរាជវង្ស និងជនដែលមានតំណែងខ្ពង់ខ្ពស់ក្នុងសង្គមនាមត្រកូល ហើយលក្ខណៈ និងនិយមន័យនៃនាមត្រកូលមានភាពស្មុគស្មាញគួរសម។ ទោះជាយ៉ាងនេះក្តី ផ្នែកដំបូងនៃឈ្មោះហាក់ដូចជាត្រូវបានចាត់ទុកថាជានាមត្រកូល ឬត្រកូល ហើយនៅពេលចុះបញ្ជីក៏ចាំបាច់ធ្វើការបែងចែកនាមត្រកូល និងនាមខ្លួន ហើយដោយផ្អែកលើលទ្ធផលនៃការសួរមតិយោបល់ដែរថា ការទទួលស្គាល់ការជ្រើសរើសឈ្មោះរបស់ប្តីប្រពន្ធជាការសមរម្យ ទើបយើងសម្រេចថា ការប្រើនាមត្រកូលរួម ឬនាមត្រកូលដោយឡែកក៏មិនមានបញ្ហាអ្វីដែរ។

### ២.៣.២ សេរីភាពក្នុងការប្រកបវិជ្ជាជីវៈ និងសិទ្ធិចូលរួមក្នុងសកម្មភាពសង្គម

ប្តីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គមរៀងៗខ្លួនបាន[30]។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រទេសជាតិ[31]។ ទោះបីជាអាពាហ៍ពិពាហ៍ជាចំណងភ្ជាប់កាតព្វកិច្ចជាមួយគ្នារវាងប្តីប្រពន្ធ និងជាចំណងចងភ្ជាប់គ្នាគ្រប់សកម្មភាពរវាងគ្នានឹងគ្នាទៅវិញទៅមកក៏ដោយ ក៏ក្រមរដ្ឋប្បវេណីបានផ្តល់សេរីភាពដល់ប្តីប្រពន្ធក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយសេរីភាពពក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សាសនាសង្គមរៀងៗខ្លួនបាន។ ប្តីនិងប្រពន្ធមានសេរីភាពធ្វើការដែលខ្លួនពេញចិត្តនឹងធ្វើ។ ប្រជាពល

---

29 មាត្រា៩៦៥, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

30 មាត្រា៩៦៧, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

31មាត្រា៣៥,កថាខណ្ឌទី១,រដ្ឋធម្មនុញ្ញ, ២៤ កញ្ញា ១៩៩៣។

រដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរដែលស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្ដីត្រូវការរបស់សង្គម[32]។ ប្តីប្រពន្ធមានសេរីភាពស្រលាញ់នឹងគាំទ្រគណបក្សនយោបាយដែលខ្លួនពេញចិត្ត។ ប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោត[33]។

**២.៣.៣ ករណីកិច្ចរួមរស់ សហការ និងសង្គ្រោះគ្នាទៅវិញទៅមក**

អាពាហ៍ពិពាហ៍គឺជាសម្ព័ន្ធភាពផ្លូវចិត្ត រាងកាយ និងសេដ្ឋកិច្ចនៃប្តីប្រពន្ធ ដូច្នេះប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយសហការគ្នា និងសង្គ្រោះគ្នាទៅវិញទៅមក។ ប្តីប្រពន្ធត្រូវមានភាពស្មើគ្នាលើទស្សនៈ មានករណីកិច្ចស្រលាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និងជួយគ្នាទៅវិញទៅមកដើម្បីឈានទៅកាន់វុឌ្ឍភាព ព្រមទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និងប្រកបដោយសុភមង្គល។

**២.៣.៤ តម្លៃនៃការងារក្នុងផ្ទះ**

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ[34]។ ការងារគេហកិច្ចត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើនៅក្រៅផ្ទះ[35]។ មានន័យថាទោះបីជាការងារដែលធ្វើនៅក្នុងផ្ទះក៏គិតជាប្រាក់កម្រៃស្មើគ្នាដូចទៅនឹងការងារដែលបានធ្វើនៅក្រៅផ្ទះផងដែរ។ ក្នុងសង្គមកម្ពុជាបច្ចុប្បន្នដោយសារបុរស និងនារីមានសមភាពយេនឌ័រ មានសិទ្ធិស្មើគ្នា ដូច្នេះបុរស និងនារីអាចមានការងារ ឬបំពេញការងារនៅក្រៅផ្ទះទាំងអស់គ្នា ឬមានតែខាងបុរសដែលជាប្តី ឬខាងស្ត្រីដែលជាប្រពន្ធជាអ្នកធ្វើការងារនៅខាងក្រៅដើម្បីទទួលបានកម្រៃចូលមកផ្ទះសម្រាប់ទ្រទ្រង់ជាភាពគ្រួសារ ដូចជាតាមស្ថាប័រដ្ឋ និងឯកជននានា ឬមានមុខរបដោយខ្លួនឯងជាដើមកម្រៃទាំងអស់នេះទោះបីជាភាគីខាងណារកបានក៏ចាត់ទុកជាកម្រៃរួមគ្នាផងដែរ។

**២.៣.៥ ករណីកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូន**

មាតាបិតាមានករណីកិច្ចចិញ្ចឹមថែរក្សាកូន អប់រំកូនឲ្យទៅជាពលរដ្ឋល្អ[36]។ ឪពុកម្តាយដែលបានបង្កើតកូនហើយមិនអាចបោះបង់កូន ឬទុកកូនចោល ឬបង្កើតកូនដើម្បីធ្វើអាជីវកម្មលក់ដូរ ឬកេងប្រវ័ញ្ចលើកម្លាំងពលកម្មកូនបានឡើយ។ ការបីបាច់ថែរក្សាកូន សំដៅលើរាល់សកម្មភាពទាំងឡាយដែលចាំបាច់សម្រាប់ការលូតលាស់ និងការពារកូនដែលជាអនីតិជនដោយរួមទាំងការផ្តល់ចំណីអាហារ សម្លៀកបំពាក់ ការស្នាក់នៅ ការឲ្យកូនចូលរៀន ការផ្តល់ការថែទាំវេជ្ជសាស្ត្រ និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងថែទាំកូនដែលជាអនីតិជនមិនឲ្យប្រព្រឹត្តបទល្មើស និងអំពើមិនត្រឹមត្រូវណាមួយ។

32 មាត្រា៣៦,ថ្មី កថាខណ្ឌទី១,រដ្ឋធម្មនុញ្ញ, ២៤ កញ្ញា ១៩៩៣។

33 មាត្រា៣៤,ថ្មី កថាខណ្ឌទី១, រដ្ឋធម្មនុញ្ញ, ២៤ កញ្ញា ១៩៩៣។

34 មាត្រា៣៦,ថ្មី កថាខណ្ឌទី៣, រដ្ឋធម្មនុញ្ញ, ២៤ កញ្ញា ១៩៩៣។

35 មាត្រា៩៨០, កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

36 មាត្រា៤, កថាខណ្ឌទី១, រដ្ឋធម្មនុញ្ញ, ២៤ កញ្ញា ១៩៩៣។

ការអប់រំកូនគឺជាការជំរុញអភិវឌ្ឍន៍ខាងបញ្ញារបស់កូន និងការផ្តល់ឲ្យកូនទទួលបានចំណេះដឹង និងជំនាញដែលចាំបាច់សម្រាប់ដឹកនាំជីវិតនៅក្នុងសង្គម ហើយការអប់រំនេះសំដៅលើទីតាំងនៃការអប់រំក្នុងផ្ទះ និងសាលារៀន។ ការដាក់ទណ្ឌកម្មលើកូនធ្វើឡើងក្នុងគោលបំណង ដើម្បីអប់រំកូនហើយអ្នកមានអំណាចមេបាគួរតែមានសិទ្ធិក្នុងការដាក់ទណ្ឌកម្មលើកូនដោយខ្លួនឯង នៅពេលដែលកូនបានប្រព្រឹត្តអំពើមិនល្អនៅក្នុងសង្គម ឬអំពើដែលពុំគប្បី ប៉ុន្តែការដាក់ទណ្ឌកម្មនេះក្នុងទំហំដែលចាំបាច់សម្រាប់ការអប់រំដល់កូនតែប៉ុណ្ណោះ[37]។ ការដាក់ទណ្ឌកម្មដែលបណ្តាលឲ្យមានគ្រោះថ្នាក់ផ្នែកផ្លូវចិត្ត ឬផ្លូវកាយដល់កូន ក្នុងនាមជាពិន័យមិនត្រូវបានអនុញ្ញាតឡើយហើយប្រសិនបើអ្នកមានអំណាចមេបាបានដាក់ទណ្ឌកម្មហួសកម្រិតនៃការចាំបាច់ចំពោះកូន គេអាចប្រកាសព្យួរទោស ឬដកហូតអំណាចមេបានោះតាមផ្លូវតុលាការ[38]។

ការអនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈ ឬអាជីវកម្ម មានន័យថា កូនអាចប្រកបវិជ្ជាជីវៈ ឬធ្វើអាជីវកម្មបាន លុះត្រាតែមានការអនុញ្ញាតពីអ្នកមានអំណាចមេបា។ ផ្ទុយទៅវិញប្រសិនបើកូនមិនអាចប្រកបវិជ្ជាជីវៈ ឬអាជីវកម្មបានឡើយ ប្រសិនបើពុំមានការយល់ព្រមពីអ្នកមានអំណាចមេបា ហើយអ្នកមានអំណាចមេបា ក៏អាចកម្រិតនូវការអនុញ្ញាត ឬការលុបចោលនូវការអនុញ្ញាតនោះបានដែរ។ ហេតុនេះសកម្មភាពអនីតិជនធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានអំណាចមេបា មានសិទ្ធិលុបចោលសកម្មភាពនោះបាន លើកលែងតែសកម្មភាពដែលទទួលបានសិទ្ធិ ឬរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ។ ទោះបីជាអ្នកមានអំណាចមេបា មានសិទ្ធិធ្វើសកម្មភាពឲ្យកូនក៏ដោយ បើសកម្មភាពរបស់អ្នកមានអំណាចមេបាបង្កើតកាតព្វកិច្ចដែលមានកម្មវត្ថុជាសកម្មភាពរបស់កូន អ្នកមានអំណាចមេបាត្រូវទទួលការយល់ព្រមពីកូននោះដែរ។

## ២.៤ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

### ២.៤.១ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬក្រោយពេលអាពាហ៍ពិពាហ៍បាន[39]។

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវបានធ្វើឡើង ដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និងដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងសិទ្ធិ និងករណីកិច្ចរបស់ប្តីប្រពន្ធ។ ទំនាក់ទំនងជាក់ស្តែងរវាងប្តីប្រពន្ធមានលក្ខណៈច្រើនបែបយ៉ាង ហើយបញ្ញត្តិនេះផ្តល់លទ្ធភាពឲ្យប្តីប្រពន្ធនូវជម្រើសដែលមានលក្ខណៈបត់បែនសមស្របទៅតាមភាពចាំបាច់របស់ប្តីប្រពន្ធជាក់លាក់។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ក៏មានអានុភាពដែលសម្របសម្រួលការពិភាក្សាអំពីអនាគតប្តីប្រពន្ធផងដែរ។

[37] មាត្រា១០៤៥, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[38] មាត្រា១០៤៨, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[39] មាត្រា៩៦៩ កថាខណ្ឌទី១, វាក្យខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវធ្វើត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ[40]។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយតម្រូវឲ្យកិច្ចសន្យានេះធ្វើជាលាយល័ក្ខណ៍អក្សរ ដោយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះនាំឲ្យមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទំនាក់ទំនងនៃសិទ្ធិ និងករណីកិច្ចលើទ្រព្យសម្បត្តិប្តីប្រពន្ធ។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្នុងករណីដែលធ្វើខុសពីប្រពន្ធទ្រព្យសម្បត្តិដែលកំណត់ច្បាប់ ដើម្បីជៀសវាងនូវផលប៉ះពាល់អាក្រក់ចំពោះផលប្រយោជន៍របស់តតិយជន។

## ២.៤.២ ប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់

ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម ជាប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់ ដោយសារតែករណីប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ដែលពាក់ព័ន្ធដល់ទំនាក់ទំនងទ្រព្យសម្បត្តិរបស់សហព័ទ្ធ។ មាត្រា៩៧២ និងមាត្រា៩៧៣នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧បានបែងចែកដែលកាន់កាប់ក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ជាពីរបែបគឺ ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។

### ក.ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដដោយឡែក គឺជាទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់សហព័ទ្ធមួយ ហើយមិនមែនជាកម្មសិទ្ធិសហព័ទ្ធម្ខាងទៀត។ ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធមានមុនពេលរៀបអាពាហ៍ពិពាហ៍ ជាទ្រព្យសម្បត្តិដែលទទួលបានតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យទាន និងទ្រព្យដែលទទួលបានតាមរយៈការចាត់ចែងទ្រព្យសម្បត្តិដោយឡែកផ្សេងទៀតនឹងត្រូវរាប់បញ្ចូលជាទ្រព្យដោយឡែក។ នៅពេលដែលជីវភាពអាពាហ៍ពិពាហ៍កាន់តែយូរទៅ មានករណីជាច្រើនដែលទ្រព្យសម្បត្តិមានមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលទទួលបានក្នុងកំឡុងពេលរៀបអាពាហ៍ពិពាហ៍ ក្លាយទៅជាមិនអាចបែងចែកច្បាស់លាស់ថា តើជាទ្រព្យដោយឡែក(ទ្រព្យសម្បត្តិរបស់បុគ្គល) ឬជាទ្រពព្យរួមហើយក៏ក្លាយទៅជាវិវាទ។ ដូច្នេះហើយវាជាការល្អប្រសិនបើយើងធ្វើបញ្ជីទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធដើម្បីបញ្ជាក់ឲ្យច្បាស់ជាមុនថា តើទ្រព្យណាខ្លះជាទ្រព្យសម្បត្តិដោយឡែក និងទ្រព្យណាខ្លះជាទ្រព្យសម្បត្តិរួម។

ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែកដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់[41]៖

- ទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។
- ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

[40] មាត្រា៩៧០, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[41] មាត្រា៩៧២, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

➢ ទ្រព្យសម្បត្តិជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិ ដែលបានមកពីទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

❖ **ប្រទានកម្ម៖** កិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឲ្យទៅភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល[42]។

ឧទាហរណ៍៖ A ដែលជាឪពុកបានឲ្យផ្ទះមួយខ្នងទៅកូន B នៅមុនពេលរៀបអាពាហ៍ពិពាហ៍ដោយបានផ្ទេរនូវកម្មសិទ្ធិ និងចុះបញ្ជីដាក់ឈ្មោះ B ជាម្ចាស់កម្មសិទ្ធិ។

❖ **សន្តតិកម្ម៖** ជាការផ្ទេរនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនឲ្យទៅសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់[43]។

ឧទាហរណ៍៖ A ដែលជាឪពុកមុនពេលស្លាប់បានធ្វើបណ្តាំមតក៍មួយច្បាប់ ដោយបានប្រគល់ដីស្រែចំនួន៥ហិតាឲ្យទៅកូនពៅឈ្មោះ B ដែលនៅលីវ។ បើទោះបីក្រោយមកទៀតកូនឈ្មោះ B បានរៀបអាពាហ៍ពិពាហ៍ក៏ដោយ ប្រសិនបើ B មិនបានកែប្រែ ឬយល់ព្រមយកដីនោះដាក់ជាកម្មសិទ្ធិរួមជាមួយសហព័ទ្ធទេ ក៏នៅតែជាទ្រព្យដោយឡែករបស់ B ដដែល។

❖ **អច្ច័យទាន៖** ជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍[44]។

ឧទាហរណ៍៖ លោក វិច្ឆកា មុនពេលស្លាប់បានធ្វើបណ្តាំមតក៍មួយច្បាប់ដោយក្នុងបណ្តាំនោះបានសរសេរថា ដីចម្ការចំនួនមួយហិតាឲ្យទៅលោក តុលា ដែលជាមិត្តភក្តិសម្លាញ់តាំងពីរៀនបឋមជាមួយគ្នា។ ក្រោយមកលោក តុលា ក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយនារីម្នាក់ឈ្មោះ បុប្ផា បើទោះបីលោក តុលា បានរៀបអាពាហ៍ពិពាហ៍ជាមួយ នារីម្នាក់ឈ្មោះ បុប្ផា ក៏ដោយក៏ដីនោះនៅតែជាកម្មសិទ្ធិរបស់លោក តុលា ដដែល ប្រសិនបើលោក តុលា មិនបានផ្ទេរកម្មសិទ្ធិ និងចុះបញ្ជីដាក់ជាកម្មសិទ្ធិរួមជាមួយ បុប្ផាដែលជាសហព័ទ្ធរបស់ខ្លួន។

**ខ.ទ្រព្យសម្បត្តិរួម**

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយណា ដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលទទួលបានពីទ្រព្យសម្បត្តិដែលសហព័ទ្ធទទួល

[42] សន្ធានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧។

[43] សន្ធានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧។

[44] សន្ធានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧។

បាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងបានមកពីទ្រព្យសម្បត្តិជាតម្លៃតដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានមកពីទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់នូវទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធដែលបានធ្វើនៅក្រៅផ្ទះ និងសហព័ទ្ធដែលមិនបានទៅធ្វើការនៅក្រៅផ្ទះ ដើម្បីរកចំណូលឲ្យគ្រួសារពិតមែន តែចំណូលអ្នកដែលបានធ្វើការនៅក្រៅផ្ទះនេះ ក៏មានចំណែកស្មើគ្នាជាមួយអ្នកដែលមិនបានទៅធ្វើការនៅក្រៅផ្ទះផងដែរ។ ពោលគឺចំណូលអ្នកដែលបានចេញទៅធ្វើការងារ ឬទៅរកស៊ីក្រៅផ្ទះនេះក៏ជាចំណូលរបស់អ្នកដែលនៅក្នុងផ្ទះមើលថែកូនចៅនៅផ្ទះដែរ។ ដោយយោងតាមមាត្រា៣៦នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ ការងារមេផ្ទះមានតម្លៃស្មើនឹងកម្រៃ ដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។

**គ. ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម**

ដោយយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា៩៧៤ ស្តីអំពី ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ចែងថា៖

១. ប្តីប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម។ សហព័ទ្ធនីមួយៗមានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន។

២. សហព័ទ្ធមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព។

៣. សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀតឲ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និងរក្សាទុកនូវទ្រព្យសម្បត្តិរួមបាន។

៤. បើការពិភាក្សាគ្នាអំពីការគ្រប់គ្រង ឬប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនបានសម្រេច ឬពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឲ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន។

ប្តីប្រពន្ធមានសិទ្ធិប្រៀប្រាស់ទ្រព្យសម្បត្តិរួម ក្នុងទំហំដែលចាំបាច់ដោយផ្អែកលើការចាំបាច់នីក្នុងជីវភាពសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ គោលការណ៍នៃប្រើសប្រាស់គ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នាដោយតម្រូវឲ្យប្តីប្រពន្ធគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នាទៅវិញទៅមក និងសហព័ទ្ធម្ខាងទៀតមានសិទ្ធិទាមទារឲ្យភាគីម្ខាងទៀតធ្វើចំណាត់ការដែលចាំបាច់សម្រាប់ថែរក្សាទ្រព្យសម្បត្តិរួម។ ជាឧទាហរណ៍ ក្នុងករណីដែលអចលនវត្ថុជាទ្រព្យសម្បត្តិរួម តែត្រូវបានចុះបញ្ជីក្រោមកម្មសិទ្ធិរបស់សហព័ទ្ធម្ខាង សហព័ទ្ធម្ខាង

ទៀតអាចទាមទរសហព័ទ្ធនោះដែលត្រូវបានចុះបញ្ជីជាម្ចាស់កម្មសិទ្ធិឲ្យសហការចុះបញ្ជីអចលនវត្ថុនោះជាកម្មសិទ្ធិអវិភាគបាន។ ប្រសិនបើប្ដីប្រពន្ធមិនអាចពិគ្រោះយោបល់គ្នាអំពីការគ្រប់គ្រងទ្រព្យសម្បត្តិ និងការប្រើប្រាស់ទ្រព្យសម្បត្តិរួមបានទេ ភាគីម្ខាងណាមួយអាចទាមទារទៅតុលាការ ឲ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមបានដើម្បីដោះស្រាយវិវាទលើការគ្រប់គ្រងទ្រព្យសម្បត្តិរវាងប្ដីប្រពន្ធ។

### ២.៤.៣ ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច

ប្ដីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ[45]៖

ក. សោហ៊ុយដើម្បីថែរក្សាជីវភាពរស់នៅរបស់ប្ដីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាលថែទាំកូនជាអាទិ៍។

ខ. កាតព្វកិច្ច និងករណីកិច្ចផ្សេងៗទៀតដែលប្ដីប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតលាយលក្ខណ៍អក្សរ ជាមួយម្ចាស់បំណុលនៅមុនពេលអំឡុងពេលអាពាហ៍ពិពាហ៍ ឬកាតព្វកិច្ច និងករណីកិច្ចផ្សេងៗទៀតដែលប្ដីប្រពន្ធម្ខាងបានទទួលបន្ទុកដោយមានការយល់ព្រមតាមលិខិតជាលាយលក្ខណ៍អក្សរពីប្រពន្ធ ឬប្ដីម្ខាងទៀតនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

គ. សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម។

ទោះបីជាកម្ពុជាអនុម័តយកប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់បប្ដីប្រពន្ធក៏ដោយ ក៏ពុំមានភាពសមរម្យក្នុងការដាក់បន្ទុកឲ្យប្ដីប្រពន្ធនីមួយៗនូវកាតព្វកិច្ចដ៏ធ្ងន់ធ្ងរដែរ ហើយមានភាពសមរម្យឲ្យទទួលខុសត្រូវចំពោះកាតព្វកិច្ចរួមគ្នាក្នុងទំហំសមរម្យមួយ ដែលទោះបីជាមើលពីខាងតតិយជនទៅ ក៏ឃើញថាសមរម្យដែរ។ កាតព្វកិច្ច និងករណីកិច្ចផ្សេងៗទៀត ទាមទារជាពិសេសនូវឲ្យមានលក្ខខណ្ឌចាំបាច់នៃលិខិតជាលាយលក្ខណ៍អក្សរ និងការព្រមព្រៀងរវាងប្ដីប្រពន្ធទាំងសងខាង ដើម្បីជៀសវាងការដាក់បន្ទុកធ្ងន់ធ្ងរទៅលើភាគីម្ខាងៗ។ ប៉ុន្តែនៅក្នុងករណីដែលអនុវត្តនូវប្រព័ន្ធទ្រព្យសម្បត្តិរួម ទោះបីជាសហព័ទ្ធម្ខាង ឬទាំងសងខាងទទួលបន្ទុកនូវកាតព្វកិច្ចក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ជាគោលការណ៍បន្ទុកនៃកាតព្វកិច្ចត្រូវជារបស់ទ្រព្យសម្បត្តិរួមដែរ ហើយកាតព្វកិច្ចនឹងក្លាយទៅជាកាតព្វកិច្ចរួមរបស់សហព័ទ្ធទាំងពីរ។

### ២.៤.៤ ការចាត់ចែងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា៩៧៦ ការចាត់ចែងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ចែងថា[46]៖

១. បើគ្មានការយល់ព្រមពីប្ដីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធមិនអាចយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងៗបានឡើយ។

---

[45] មាត្រា៩៧៥, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[46] មាត្រា៩៧៦, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

២. បើស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីជីវភាពរស់នៅ នោះប្តីប្រពន្ធណាម្ខាងបានលក់ ឬធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ។

៣. ក្នុងករណីដែលប្តី ឬប្រពន្ធណាម្ខាងបានលក់ ឬធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និងគ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រមអាចទាមទារឲ្យតុលាការលុបចោលនូវការចាត់ចែងនោះ នៅក្នុងអំឡុងពេលពីរឆ្នាំគិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ និងក្នុងអំឡុងពេលមួយឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជាទ្រព្យសម្បត្តិផ្សេង។

### ២.៤.៥ ការស្នាក់អាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

ការស្នាក់អាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក[47]៖

១. ប្តីប្រពន្ធអាចអាស្រ័យនៅអចលវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើប្រាស់សម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន។

២.នៅក្នុងករណីដែលប្តីប្រពន្ធម្ខាងបានអាស្រ័យនៅអចលវត្ថុដែលដែលជាទ្រព្យសម្បដោយឡែករបស់សហព័ទ្ធម្ខាងទៀតសម្រាប់អាស្រ័យនៅ ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏អាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដែរ។

## ២.៥ មូលហេតុបញ្ចប់អាពាហ៍ពិពាហ៍

### ២.៥.១ មរណភាពរបស់សហព័ទ្ធ

អាពាហ៍ពិពាហ៍នឹងត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិ ក្នុងករណីដែលមានសហព័ទ្ធណាម្ខាងបានទទួលមរណភាពដោយកត្តាណាមួយ។ ប៉ុន្តែដើម្បីបញ្ជាក់បានថាមានសហព័ទ្ធណាបានទទួលមរណភាព ហើយអាពាហ៍ពិពាហ៍នឹងត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិនោះ តម្រូវអ្នកដែលពាក់ព័ន្ធនឹងមរណជននោះត្រូវបំពេញនៃនីតិវិធីក្នុងការបញ្ជាក់អំពីមរណជននោះឲ្យបានត្រឹមត្រូវ។

បុគ្គលដែលទទួលខុសត្រូវជាអ្នករាយការណ៍អំពីមរណភាពរបស់មរណជន ទៅមន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់ ឬទីកន្លែងរស់នៅជាប់លាប់នៃរបស់មរណជន ត្រូវបានកំណត់តាមអាទិភាពដូចខាងក្រោមនេះ[48]៖

---

[47] មាត្រា៩៧៧, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[48] មាត្រា៣៥, កថាខណ្ឌទី១, អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន,លេខ១០៣ អនក្រ កប, ២៩ ធ្នូ ២០០០។

- សហព័ទ្ធរបស់មរណជន។
- ញាតិសន្តានរបស់មរណជន។
- អ្នកជិតខាង ។
- អ្នកមានភារកិច្ចនៅក្រសួង ប្រធានស្ថាប័ន អង្គភាពរបស់អ្នកស្លាប់។

ទីកន្លែងចុះសៀវភៅមរណភាពរបស់មរណជនគឺឃុំ ឬសង្កាត់នៃមរណជន។

បើមានអ្នករស់នៅឃុំ ឬសង្កាត់ណាមួយបានទៅស្លាប់នៅឃុំ ឬសង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់របស់អ្នកស្លាប់រស់នៅដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់ ឲ្យទៅយកសពកធ្វើបុណ្យ និងចុះសៀវភៅមរណភាពនៅឃុំ ឬសង្កាត់នៃអ្នកស្លាប់នោះស្នាក់នៅជាប់លាប់[49]។

ក្នុងរណីដែលអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬអ្នកស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ត្រូវចាត់ចែងបូជា ឬបញ្ចុះសពនោះ និងចុះសៀវភៅមរណភាពក្នុងឃុំ ឬសង្កាត់នោះ[50]។

រយៈពេលចុះសៀវភៅមរណភាព៖ អ្នករាយការណ៍ត្រូវដាក់ពាក្យចុះសៀវភៅមរណភាពក្នុងរយៈពេល ១៥ថ្ងៃក្រោយពីថ្ងៃទទួលមរណភាព[51]។ បើមានអ្នកស្លាប់ទុកឲ្យហួសរយៈពេល១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅមរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ទៅសុំសាលក្រមពីតុលាការខេត្ត-ក្រុងសាមី រួចយកសាលក្រមនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅមរណភាព[52]។

ក្រោយពេលចុះបញ្ជីមរណភាពរួចរាល់ហើយ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវចេញសំបុត្រមរណភាពច្បាប់ដើម១ច្បាប់ជូនអ្នកស្នើសុំ និងសេចក្តីចម្លងតាមការស្នើសុំរបស់អ្នកស្នើសុំ។

### ២.៥.២ មោឃភាពអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ដែលស្របច្បាប់ពុំអាចមោឃភាពបានទេ លើកលែងតែអាពាហ៍ពិពាហ៍នោះសាមីខ្លួនបានប្រព្រឹត្តខុស នាំឲ្យអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកជាមោឃភាព ដោយសារតែមានមូលហេតុដូចក្នុងករណីខាងក្រោម។

#### ក. គ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍

ការរៀបអាពាហ៍ពិពាហ៍ដែលគ្មានឆន្ទៈ រវាងភាគីដោយសារភាន់ច្រឡំលើមនុស្ស ឬដោយការបង្ខិតបង្ខំ និងមូលហេតុផ្សេងៗទៀតដែលនាំឲ្យអាពាហ៍ពិពាហ៍ត្រូវទុកជាមោឃភាពបាន។ ការភាន់ច្រឡំអាចជាការច្រឡំ

[49] មាត្រា៣៧, កថាខណ្ឌទី១, អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន,លេខ១០៣ អនក្រ កប, ២៩ ធ្នូ ២០០០។
[50] មាត្រា៣៧, កថាខណ្ឌទី២, អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន,លេខ១០៣ អនក្រ កប, ២៩ ធ្នូ ២០០០។
[51] មាត្រា៣៥, កថាខណ្ឌទី៣, អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន,លេខ១០៣ អនក្រ កប, ២៩ ធ្នូ ២០០០។
[52] មាត្រា៤០, អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន,លេខ១០៣ អនក្រ កប, ២៩ ធ្នូ ២០០០។

ចំពោះបុគ្គលដែលមានឋានៈតួនាទី ឬចំពោះបុគ្គលដែលមានមុខមាត់ស្រដៀងគ្នា។ ចំពោះការបង្ខំអាចជាការបង្ខំខាងផ្លូវកាយ ឬផ្លូវចិត្តរបស់ភាគីដែលត្រូវបានគេបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ ការរៀបអាពាហ៍ពិពាហ៍ដោយការបង្ខំនេះអាចចាត់ទុកជាមោឃៈបាន និងមានរយៈពេលសម្រាប់ប្ដឹងសុំលុបអាពាហ៍ពិពាហ៍នោះចោល បើការប្ដឹងនោះបានធ្វើក្នុងរយៈពេល៦ខែគិតពីថ្ងៃដែលគេលែងបង្ខំនោះមក។ ជាឧទាហរណ៍ "A" បានចាប់ចិត្តស្រលាញ់ហើយចង់រៀបការជាមួយនឹង "B" ប៉ុន្តែ "A" បានបង្កើតអាពាហ៍ពិពាហ៍ជាមួយ "C" ដោយគិតថា"C" គឺជា "B" ។ ក្នុងករណីនេះគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍នឹង "C" ទេ អាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើងដោយការភាន់ច្រឡំ។ ដូចនេះអាពាហ៍ពិពាហ៍រវាង "A" និង "C" ត្រូវចាត់ទុកជាមោឃៈ ដោយមូលហេតុ "A" គ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍។

**ខ. អាពាហ៍ពិពាហ៍ដែលមិនបានគោរពតាមនីតិវិធី**

ការរៀបអាពាហ៍ពិពាហ៍ដែលគូភាគីពុំបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ដូចជា ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ដែលគោរពតាមបញ្ញត្តិស្ដីពីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍។ ប៉ុន្តែប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះទេ គឺនៅតែអានុភាពនៃអាពាហ៍ពិពាហ៍មិនត្រូវបានរារាំងដោយហេតុនោះឡើយ[53]។ ជាឧទាហរណ៍ "A" ចង់រៀបការជាមួយ "B" ប៉ុន្តែ "B" មិនចង់រៀបការជាមួយ "A" នោះទេ។ ដោយលីដូច្នេះ ម្ដាយរបស់ "B" តែងតែធ្វើបាបគម្រាមកំហែង "B" គ្រប់បែបយ៉ាង។ បន្ទាប់មក "A" បានបង្ខំឲ្យ "B" ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ដោយឲ្យចុះហត្ថលេខានៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ហើយបានប្រាប់មន្ត្រីអត្រានុកូលដ្ឋានថា "B" កំពុងខឹងទើបមិនព្រមចុះហត្ថលេខាលើកិច្ចសន្យាអាពាហ៍ពិពាហ៍។ ក្នុងករណីនេះ អាពាហ៍ពិពាហ៍រវាង "A" និង "B" ត្រូវចាត់ទុកជាមោឃៈ ដោយហេតុថា "B" គ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ឡើយ ។

**២.៥.៣ ការលុបចោលអាពាហ៍ពិពាហ៍**

ការលុបចោលអាពាហ៍ពិពាហ៍ គឺជាការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវ មិនស្របច្បាប់ ឬអាពាហ៍ពិពាហ៍នោះធ្វើផ្ទុយពីលក្ខខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍។ ការលុបចោលអាពាហ៍ពិពាហ៍ត្រូវយោងទៅតាមបញ្ញត្តិដែលច្បាប់បានចែង ព្រោះជាការធ្វើឲ្យប៉ះពាល់យ៉ាងធំធេងទាំងផ្លូវកាយ ផ្លូវចិត្ត និងកិត្តិយសដល់គូភាគី ឪពុកម្ដាយ និងញាតិសន្តានទាំងសងខាងទៀតផង។ ប៉ុន្តែការលុបចោលអាពាហ៍ពិពាហ៍នេះក៏មានសារៈសំខាន់ដែរ ប្រសិនអាពាហ៍ពិពាហ៍នោះធ្វើឲ្យប៉ះពាល់យ៉ាងធំធេង ក្នុងករណីនេះភាគីនីមួយៗ ឪពុកម្ដាយ ញាតិសន្តានរបស់ជននោះ ឬតំណាងអយ្យការអាចទាមទារទៅតុលាការឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដោយមូលហេតុត្រឹមត្រូវ។ ចំពោះអាពាហ៍ពិពាហ៍រវាងជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ ឬអាពាហ៍

[53] មាត្រា៩៥៤, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

ពិពាហ៍រវាងញាតិថ្នាក់ជិត បុគ្គលដែលមានសិទ្ធិទាមទារឲ្យលុបចោល គឺជាភាគីណាមួយនៃអាពាហ៍ពិពាហ៍ ញាតិរបស់ជននោះ ឬតំណាងអយ្យការ រីឯចំពោះករណីទ្វេពន្ធភាព ឬការបំពានអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីវិញសហព័ទ្ធរបស់ភាគី ឬសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុនក៏អាចទាមទារឲ្យលុបចោលបានដែរ។ ប៉ុន្តែចំពោះតំណាងអយ្យការដែលជាអ្នកតំណាងឲ្យផលប្រយោជន៍សាធារណៈ សិទ្ធិទាមទារឲ្យលុបចោលរបស់តំណាងអយ្យការនោះត្រូវរលត់ ប្រសិនបើសហព័ទ្ធម្ខាងទទួលមរណភាព។ ក្នុងករណីដែលជនមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានដល់អាយុរៀបអាពាហ៍ពិពាហ៍ សិទ្ធិទាមទារឲ្យលុបចោលត្រូវរលត់។ បើទោះជាដូច្នេះក្តី ជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ មានសិទ្ធិលុបចោល និងសិទ្ធិធ្វើសច្ចានុម័ត ក្នុងអំឡុងពេលបីខែបន្ទាប់ពីជននោះដល់អាយុរៀបអាពាហ៍ពិពាហ៍។ ប្រសិនបើជននោះបានធ្វើសច្ចានុម័តលើអាពាហ៍ពិពាហ៍ ជននោះមិនអាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបានទេ។ ចំណែកឯការបំពានអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀតពុំអាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍បានឡើយ ប្រសិនបើរយៈពេល១២០ថ្ងៃបានកន្លងផុតគិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនបានរំលាយ ឬលុបចោល ឬប្រសិនបើនារីមានផ្ទៃពោះក្រោយពីរៀបអាពាហ៍ពិពាហ៍ថ្មីទៀត។ ចំពោះបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគំរាមអាចទាមទារទៅតុលាការឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន។ ចំពោះការឆបោក ការគំរាមគឺសំដៅលើការធ្វើឲ្យភាគីម្ខាងទៀតយល់ព្រមរៀបអាពាហ៍ពិពាហ៍ដោយសារមធ្យោបាយមួយដែលខុសច្បាប់ ដោយការបោកប្រាស់ឲ្យជននោះធ្លាក់ទៅក្នុងការភាន់ច្រឡំ ឬការធ្វើឲ្យជននោះធ្វើតាមដោយការជូនដំណឹងអំពីភាពអាក្រក់ទៅភាគីម្ខាងទៀត។ ការឆបោកនេះអាចមានករណីដូចជាអាពាហ៍ពិពាហ៍ដែលត្រូវបានកើតឡើង ដោយសារមធ្យោបាយដែលត្រូវបានប្រើប្រាស់ដែលមានលក្ខណៈឆបោកពាក់ព័ន្ធទៅនឹងអសមត្ថភាពផ្លូវភេទ ឬចំណុចសំខាន់ៗផ្សេងទៀតជាសត្យានុម័ត ឬជាអត្តនោម័ត ឬដោយពាក្យសម្តីឬអំពើគំរាមកំហែងជាដើម។ សិទ្ធិលុបចោលនូវអាពាហ៍ពិពាហ៍ដោយការឆបោក ឬគំរាមនេះត្រូវរលត់បើភាគីបានរកឃើញការឆបោក ឬបើអំឡុងបីខែបានកន្លងផុតក្រោយពីបានរួចផុតពីការគំរាមឬបើបានធ្វើសច្ចានុម័តលើអាពាហ៍ពិពាហ៍ដោយការឆបោក ឬគំរាមនោះ។

### ២.៥.៤ អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួចរាល់ហើយប្តី និងប្រពន្ធតែងតែទទួលបាននូវអានុភាពពីការរៀបអាពាហ៍ពិពាហ៍ជាច្រើនទាំងទ្រព្យសម្បត្តិ និងសិទ្ធិផ្សេងៗ ក្នុងការរួមចំណែកគ្រប់គ្រងគ្រួសារ ប៉ុន្តែអានុភាពនោះនឹងរលត់បាត់ទៅវិញ បើអាពាហ៍ពិពាហ៍នោះត្រូវលុបចោលហើយនាំឲ្យអស់សិទ្ធិ ឬអានុភាពដូចខាងក្រោម៖

- ការលុបចោលអាពាហ៍ពិពាហ៍ពុំមានអានុភាពទៅលើអតីតកាលឡើយ។

- ភាគីដែលមិនដឹងអំពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ ប្រសិនបើទទួលទ្រព្យសម្បត្តិដោយការរៀបអាពាហ៍ពិពាហ៍នោះត្រូវសងទ្រព្យសម្បត្តិនោះត្រឹមកម្រិតដែលបានទទួល។
- ភាគីដែលបានដឹងអំពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ ត្រូវសងផលប្រយោជន៍ទាំងអស់ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍នោះ។ ប៉ុន្តែប្រសិនបើភាគីម្ខាងទៀតទុច្ចរិតវិញត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតដែលបានទាមទារនោះ[54]។

ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ និងទទួលបានអានុភាពពីការរៀបអាពាហ៍ពិពាហ៍មកប្តី និងប្រពន្ធអាចរស់នៅជាមួយគ្នាយ៉ាងរីករាយ និងសុភមង្គល ប៉ុន្តែទោះជាយ៉ាងណាអាពាហ៍ពិពាហ៍នោះត្រូវគោរពតាមបញ្ញត្តិច្បាប់ដើម្បីធានាថាវាមិនអាចត្រូវបានលុបចោល ឬទុកជាមោឃៈតាមមធ្យោបាយផ្លូវច្បាប់។ សុពលភាពនៃអាពាហ៍ពិពាហ៍នឹងបន្តរហូតដល់សេចក្តីសម្រេចចុងក្រោយរបស់តុលាការ ដែលសម្រេចលុបចោលចូលជាស្ថាពរ។ ទោះបីជាមានការសម្រេចចុងក្រោយរបស់តុលាការក៏ដោយ ការលុបចោលនេះនឹងមិនមានអានុភាពអ្វីដល់ការកើតឡើងកាលពីអតីតកាលនោះទេ ប៉ុន្តែនឹងមានអានុភាពត្រឹមតែការរំលាយអាពាហ៍ពិពាហ៍សម្រាប់អនាគតប៉ុណ្ណោះ។

ទ្រព្យសម្បត្តិដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍ រួមមានទ្រព្យសម្បត្តិដែលត្រូវបានធ្វើប្រទានកម្មនៅពេលរៀបអាពាហ៍ពិពាហ៍ និងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈសន្តតិកម្ម អច្ច័យទាន និងផលប្រយោជន៍ពីការធានារ៉ាប់រងជីវិត។ រីឯផលប្រយោជន៍ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍ រួមមានផលប្រយោជន៍លើទ្រព្យសម្បត្តិទាំងអស់ដូចជា លំនៅឋាន ថ្លៃចំណាយលើម្ហូបអាហារ ការសិក្សា និងការកម្សាន្តជាដើម។

### ២.៥.៥ អវត្តមាន ឬការប្រកាសការបាត់ខ្លួន

ក្នុងករណីដែលស្ថានភាពមិនអាចដឹងថាបុគ្គលដែលអវត្តមាននៅរស់ ឬទទួលមរណភាពនៅតែបន្តអស់រយៈពេលយូរ ទំនាក់ទំនងគតិយុត្តពាក់ព័ន្ធនឹងបុគ្គលនោះមិនច្បាស់លាស់ ដែលធ្វើឲ្យមានការលំបាកដល់ជនពាក់ព័ន្ធ។ ឧទាហរណ៍សហព័ទ្ធដែលនៅរស់នោះមិនអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបាន សន្តតិជនមិនអាចស្នងទ្រព្យសម្បត្តិដោយសន្តតិកម្មបាន ហើយត្រូវគ្រប់គ្រងទ្រព្យសម្បត្តិដោយមិនដឹងទីបញ្ចប់ ដែលជាការមិនត្រឹមត្រូវ ដូច្នេះហើយបានជាបង្កើតឲ្យមានរបបប្រកាសអំពីការបាត់ខ្លួន ដោយចាត់ទុកថាបុគ្គលនោះបានទទួលមរណភាព។ ដើម្បីមានភាពងាយស្រួលក្នុងការសិក្សាយើងសូមធ្វើការបែងចែកការបាត់ខ្លួន ចំនួនពីរករណី គឺការបាត់ខ្លួនក្នុងករណីធម្មតា ចំណុច(ក) និងបាត់ខ្លួនក្នុងករណីពិសេស ចំណុច(ខ)។

[54] មាត្រា៩៦៤, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

**ក.ការបាត់ខ្លួនក្នុងករណីធម្មតា**

ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេលប្រាំឆ្នាំ តុលាការអាចប្រកាសថា បុគ្គលនោះបានបាត់ខ្លួនតាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មត់ថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន[55]។

ការបាត់ខ្លួនធម្មតាដែលត្រូវមានលក្ខខណ្ឌមិនដឹងថានៅរស់ ឬទទួលមរណភាពរយៈពេលយ៉ាងតិចប្រាំឆ្នាំ ហើយតុលាការត្រូវប្រកាសអំពីការបាត់ខ្លួននោះតាមពាក្យរបស់អ្នកដាក់ពាក្យសុំ។ នៅក្នុងករណីដែលសាច់ញាតិគ្រួសាររបស់អ្នកអវត្តមានពុំបានដាក់ពាក្យសុំទេ មេឃុំ ឬចៅសង្កាត់ ព្រះរាជអាជ្ញាក៏ពុំអាចដាក់ពាក្យសុំបាន ពីព្រោះសាច់ញាតិគ្រួសាររបស់អ្នកបាត់ខ្លួននោះកំពុងរង់ចាំអ្នកអវត្តមាននោះត្រឡប់មកវិញ។

**ខ. ការបាត់ខ្លួនក្នុងករណីពិសេស**

ក្នុងករណីដែលបុគ្គលចូលទៅក្នុងតំបន់មានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬបុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឲ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននោះនៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេលមួយឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬក្រោយពីគ្រោះថ្នាក់ផ្សេងទៀតនោះបានកន្លងផុតទៅ[56]។

**គ. អានុភាពនៃការប្រកាសបាត់ខ្លួន**

ក្រោយពេលតុលាការប្រកាសអំពីការបាត់ខ្លួន អ្នកដែលបានបាត់ខ្លួនត្រូវចាត់ទុកថា បានទទួលមរណៈ ហើយសហព័ទ្ធដែលនៅរស់មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ថ្មីបាន។ ក្នុងករណីដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោលក្រោយពេលសហព័ទ្ធរបស់បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួននោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកផ្សេងហើយ អាពាហ៍ពិពាហ៍មុនត្រូវបានរលាយដោយសារអាពាហ៍ពិពាហ៍ក្រោយនោះ[57]។ មានន័យថា ក្នុងករណីដែលបានលុបចោលអំពីការប្រកាសបាត់ខ្លួន ក្រោយអាពាហ៍ពិពាហ៍ម្តងទៀតរបស់សហព័ទ្ធមានតែអាពាហ៍ពិពាហ៍ក្រោយនេះទេដែលមានអានុភាព(ទោះបីជាភាគីសុចរិតក៏ដោយ ទុច្ចរិតក៏ដោយ) ហើយមិនទទួលស្គាល់អាពាហ៍ពិពាហ៍មុនទេ។ ទោះជាអាពាហ៍ពិពាហ៍ក្រោយត្រូវបានធ្វើឡើងដោយឆន្ទៈទុច្ចរិតរបស់ភាគីសងខាង ឬដោយភាគីណាម្ខាងក៏ដោយក្រោយមកទៀត ទោះជាបុគ្គលដែលបានបាត់ខ្លួននោះត្រឡប់មកវិញក៏ដោយ បើភាគីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយមានបំណងចង់បន្តអាពាហ៍ពិពាហ៍នោះត្រូវគោរពឆន្ទៈរបស់ភាគីទាំងសងខាងនៃអាពាហ៍ពិពាហ៍នោះ។

[55] មាត្រា៤១,កថាខណ្ឌ១ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[56] មាត្រា៤១,កថាខណ្ឌ២ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[57] មាត្រា៤៤,កថាខណ្ឌ៤ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

### ២.៥.៦ ការលែងលះ

**ក. មូលហេតុនៃការលែងលះ**

ប្តីប្រពន្ធ អាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន តែក្នុងករណីដែលបានកំណត់ដូចខាងក្រោម៖[58]

- បើបានប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ។
- បើបានបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ។
- បើមិនដឹងថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាងមួយឆ្នាំ។
- បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាងមួយឆ្នាំផ្ទុយនឹងគោលបំណងអាពាហ៍-ពិពាហ៍។
- ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍បានបែកបាក់ ហើយគ្មានសង្ឃឹមថាអាចបដិទានឡើងវិញបាន។

បើបានប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ៖ យុត្តិសាស្ត្រប្រទេសជប៉ុនបានឲ្យនិយន័យ "អំពើផិតក្បត់" គឺជាការមានចំណងផ្លូវភេទនឹងបុគ្គលផ្សេងក្រៅពីសហព័ទ្ធ។ និយមន័យនៃយុត្តិសាស្ត្រប្រទេសជប៉ុននេះក៏មានន័យដូចនិយមន័យនៃមាត្រា៧ នៃច្បាប់ស្តីពីឯកពន្ធភាព នៅប្រទេសកម្ពុជាដែរ "អំពើផិតក្បត់" គឺជាការរួមសវនកិច្ចរវាងបុរស ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសវនកិច្ចរវាងស្ត្រី ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។

**ខ. ការលែងលះដោយការព្រមព្រៀង**

ភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន ករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា។ ប៉ុន្តែតុលាការអាចឲ្យលែងលះគ្នាបាន ក្រោយពីយល់ឃើញថាភាគីសងខាងមានបំណងពិតប្រាដកក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍[59]។ ភាគីទាំងពីរពុំចាំបាច់បង្ហាញមូលហេតុណាមួយដូចដែលមានចែងនៅក្នុងមាត្រា៩៧៨នៃក្រមរដ្ឋប្បវេណីបច្ចុប្បន្ននោះទេ ប៉ុន្តែផ្ទុយទៅវិញតុលាការធ្វើការស៊ើបអង្កេតដើម្បីកំណត់ថា តើសំណើនៃការលែងលះនោះធ្វើឡើងដោយភាគីមានបំណងពិតប្រាកដដោយស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍។ ប្រសិនបើតុលាការរកឃើញថា សំណើរួមគ្នានេះធ្វើឡើងដោយស្ម័គ្រចិត្តនោះ តុលាការអាចចេញសាលក្រមឲ្យលែងលះគ្នាបាន។ សំណើលែងលះគ្នាដោយមានការយល់ព្រមទៅវិញទៅមកមានន័យថា បើគ្មានការបង្ខិតបង្ខំទេ ភាគីទាំងពីរបានឈានដល់ការ

---

[58] មាត្រា៩៧៨,កថាខណ្ឌ១ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

[59] មាត្រា៩៧៩, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

ព្រមព្រៀងគ្នាទៅលើបញ្ហាទាំងអស់ ដែលត្រូវសម្រេចទាក់ទងនឹងការបញ្ចប់អាពាហ៍ពិពាហ៍។ បញ្ហាទាំងអស់នោះរួមមាន បញ្ហាសេដ្ឋកិច្ច ដូចជាការបែងចែកទ្រព្យសម្បត្តិ អាហារកាតព្វកិច្ច និងសេចក្ដីសម្រេចទាក់ទងនឹងការថែរក្សាកូន និងការផ្គត់ផ្គង់ដល់កូនបើសិនជាមានកូន។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ដើម្បីឲ្យការរៀបពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរមានលក្ខណៈផ្លូវច្បាប់ និងទទួលស្គាល់ដោយច្បាប់តម្រូវឲ្យភាគីនៃអាពាហ៍ពិពាហ៍ទាំងអស់ដែលបានមានបំណងរៀបអាពាហ៍ពិពាហ៍ត្រូវបំពេញលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាក់ស្ដែងនៅកម្ពុជានាពេលកន្លងមក និងបច្ចុប្បន្ននេះប្រជាពលរដ្ឋខ្មែរ តែងតែប្រារព្ធពិធីរៀបអាពាហ៍ពិពាហ៍ដែលអាពាហ៍ពិពាហ៍នោះខ្លះកើតឡើងតាមរយៈឪពុកម្ដាយជាអ្នករៀបចំផ្សំផ្គុំ និងខ្លះទៀតកើតឡើងតាមឆន្ទៈរវាងបុរស និងនារីដែលជាភាគីនៃអាពាហ៍ពិពាហ៍ផ្ទាល់តែម្ដង ប៉ុន្តែបញ្ហាចោទត្រង់ថា ការរៀបអាពាហ៍ពិពាហ៍ទាំងនោះ គឺជាការរៀបអាពាហ៍ពិពាហ៍ដែលមានលក្ខណៈផ្លូវច្បាប់ ឬគ្រាន់តែជាការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីរបស់ប្រជាជនខ្មែរ។ យើងសង្កេតឃើញថា ជាធម្មតាការរៀបអាពាហ៍ពិពាហ៍ភាគច្រើនគឺគ្រាន់តែបានបំពេញនូវលក្ខខណ្ឌមួយចំនួនតាមប្រពៃណី និងលក្ខខណ្ឌផ្លូវច្បាប់មួយចំនួនប៉ុណ្ណោះ ដែលធ្វើឲ្យយើងសន្និដ្ឋានបានថា អាពាហ៍ពិពាហ៍នោះពុំទាន់មានអានុភាពតាមផ្លូវច្បាប់មួយរយភាគរយនៅឡើយ។ ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយជាអាពាហ៍ពិពាហ៍ស្របតាមច្បាប់ និងទទួលស្គាល់ដោយច្បាប់កម្ពុជា លុះត្រាតែគ្រួសារ និងភាគីនៃអាពាហ៍ពិពាហ៍គោរព និងបំពេញលក្ខខណ្ឌតាមផ្លូវច្បាប់មួយចំនួន ដូចជា អាពាហ៍ពិពាហ៍ត្រូវធ្វើឡើងដោយភាគីទាំងសងខាងដល់នីតិភាព មានអាយុគ្រប់រៀបអាពាហ៍ពិពាហ៍(ដប់ប្រាំបីឆ្នាំ) ឬភាគីម្ខាងបានដល់នីតិភាព និងភាគីម្ខាងទៀតជាអនីតិជន តែត្រូវបានទទួលការយល់ព្រមពីអាណាព្យាបាលសម្រាប់អនីតិជននោះ។ មួយវិញទៀតភេទនៃភាគីនៃពាហ៍ពិពាហ៍ត្រូវតែជាភេទផ្ទុយគ្នា(បុរស និងនារី) និងស្របតាមឆន្ទៈបុរស និងនារី និងការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន ការហាមឃាត់រៀបអាពាហ៍ពិពាហ៍ញាតិលោហិតខ្សែផ្ទាល់ និងញាតិពន្ធជាដើម។ ទោះបីជាបានបំពេញនូវលក្ខខណ្ឌគ្រឹះមួយចំនួននេះហើយក៏ដោយ ក៏នៅមានលក្ខខណ្ឌទម្រង់ដែលជាលក្ខខណ្ឌនៃនីតិវិធីដើម្បីសុំច្បាប់ការអនុញ្ញាតរៀបអាពាហ៍ពិពាហ៍នៅដំណាក់កាលអាជ្ញាធរមូលដ្ឋានជាចាំបាច់ផងដែរ ដូចជាការដាក់ពាក្យសុំអនុញ្ញាតរៀបអាពាហ៍ពិពាហ៍ ការចេញប័ណ្ណប្រកាសជាសាធារណៈ ត្រូវគោរពតាមរយៈពេលនៃការបិទប័ណ្ណប្រកាសជាសាធារណៈសម្រាប់អ្នកមានសិទ្ធិប្ដឹងជំទាស់នឹងអាពាហ៍ពីពហ៍នោះ និងចុងក្រោយគឺជាការចុះសំបុត្រអាពាហ៍ពិពាហ៍ដែលជានីតិវិធីចាំបាច់នៃការរៀបអាពាហ៍ដែលស្របច្បាប់។ អាពាហ៍ពិពាហ៍គឺជាចំណងភ្ជាប់រវាងបុរស និងនារីឲ្យបំពេញនូវកាតព្វកិច្ច សិទ្ធិ និងករណីកិច្ចមួយចំនួនដើម្បីទ្រទ្រង់ជីវភាពគ្រួសារ ក៏ដូចជាការទទួលខុសត្រូវលើកូនៗដែលជាបច្ឆាញាតិដែលឪពុកម្ដាយគ្រប់រូបមានកាតព្វកិច្ច មើលថែទំនប់បម្រុងគ្រប់យ៉ាងដល់ពួកគេ និងជាពិសេសត្រូវផ្ដល់អាហារកាតព្វកិច្ចជាចំបាច់សម្រាប់ពួកគេដូចជាការបញ្ជូនកូនទៅរៀន រ៉ាប់រងលើការចំណាយថ្លៃសិក្សារបស់កូនៗជាដើម។ បន្ថែមពីនេះប្ដី ឬប្រពន្ធត្រូវចេះសហការគ្នា ជួយគ្នាទៅវិញទៅមក ដោយផ្ដល់សិទ្ធិសេរីភាពដល់គ្នា គោរពនូវឆន្ទៈ

គ្រួសារក្នុងការប្រកបរបរត្រឹមត្រូវ និងចេះគ្រប់គ្រងទ្រព្យសម្បត្តិដែលមានមុនពេលពេលរៀបអាពាហ៍ពិពាហ៍និង ក្រោយពេលរៀបអាពាហ៍ពិពាហ៍ គោរពនូវកម្មសិទ្ធិរួម និងកម្មសិទ្ធិបុគ្គលដើម្បីបង្កើតគ្រួសារមួយដែលមាន សុភមង្គល និងមានភាពសុខដុម។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីពួកខ្ញុំទាំងពីរនាក់បានសិក្សាស្រាវជ្រាវ និងសរសេរចងក្រងសៀវភៅនេះមក ពួកយើងទាំងពីរនាក់យល់ឃើញថាការរៀបអាពាហ៍ពិពាហ៍មួយឲ្យបានត្រឹមត្រូវតាមផ្លូវច្បាប់ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះថាប្រសិនបើគ្រាន់តែរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីតាមទំនៀមទម្លាប់គឺមិនទានគ្រប់គ្រាន់មាននៅឡើយទេ ពោលគឺធ្វើឲ្យអាពាហ៍ពិពាហ៍នោះនឹងខ្វះនូវធាតុច្បាប់ និងមិនមានអានុភាពតាមផ្លូវច្បាប់ និងមិនទទួលស្គាល់ដោយច្បាប់នោះទេ។ បើទោះបីជាអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់មានសសារៈសំខាន់យ៉ាងណាក៏ដោយ ក៏យើងនៅមើលឃើញថា ការរៀបអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋខ្មែរមួយចំនួនធំ ជាពិសេសនៅតាមជនបទគឺពុំទានមានអានុភាពតាមផ្លូវច្បាប់គ្រប់គ្រាន់នៅឡើយទេ ជាក់ស្តែងគឺគ្រាន់តែជាការបំពេញនូវលក្ខខណ្ឌមួយចំនួននៃអាពាហ៍ពិពាហ៍ ពោលគឺមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ដែលជាកត្តាដ៏សំខាន់សម្រាប់ចំណងអាពាហ៍ពិពាហ៍ ហើយក៏ទទួលស្គាល់តាមផ្លូវច្បាប់ផងដែរ។

ដើម្បីឲ្យការរៀបអាពាហ៍របស់ប្រជាពលរដ្ឋខ្មែរដែលមានលក្ខណៈស្របច្បាប់ ប្រជាពលរដ្ឋដែលមានបំណងរៀបអាពាហ៍ពិពាហ៍គួរតែពិភាគ្សាជាមួយអាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរដែលទទួលបន្ទុកលើអាពាហ៍ពាហ៍ពិពាហ៍ឲ្យបានម៉តចត់ជៀសវាងការរៀបអាពាហ៍ពិពាហ៍មួយដែលគ្រាន់តែជាការបំពេញតាមទំនៀមទម្លាប់ប្រពៃណីប៉ុណ្ណោះ។ ការគោរពទៅតាម ឬបំពេញនូវលក្ខខណ្ឌនៃច្បាប់បានផ្តល់ផលប្រយោជន៍ ដល់សហព័ទ្ធក្នុងតតាំងជាមួយនឹងតតិយជន ក៏ដូចជាការពារផលប្រយោជន៍សម្រាប់គ្រួសារក្នុងការគ្រប់គ្រង់ទ្រព្យសម្បត្តិក្នុងជីវភាពរស់នៅរបស់សហព័ទ្ធទាំងសងខាង។ បន្ថែមលើសពីនេះទៀតអាពាហ៍ពិពិពាហ៍គប្បីតែធ្វើឡើងស្របតាមឆន្ទៈរបស់ភាគី និនងជៀសវាងការតៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំរបស់ឪពុកម្តាយ ដែលជាហេតុធ្វើឲ្យតែងកើតមាននូវបញ្ហានានា និងជាពិសេសវាខុសទៅនឹងលក្ខខណ្ឌនៃច្បាប់។

ដោយយោងតាមការយល់ឃើញរបស់ខ្ញុំបាទទាំងពីរនាក់ បុគ្គលដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ត្រូវគោរព និងបំពេញលក្ខខណ្ឌឲ្យបានត្រឹមត្រូវ និងជាពិសេសជាស្នើសុំដល់អាជ្ញាធរដែលដែលទទួលើបន្ទុក ឬអាជ្ញាធរពាក់ព័ន្ធទាំងអស់ នៅពេលដែលមានប្រជាពលរដ្ឋមកស្នើសុំលិខិតរៀបអាពាហ៍ពិពាហ៍ អាជ្ញាធរដែលមានសមត្ថិច្ច គប្បីពិនិត្យឲ្យបានម៉តចត់នូវភាគីទាំងសងខាងដែលមកស្នើសុំរៀបអាពាហ៍ពិពាហ៍គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមស្របទៅតាមច្បាប់តម្រូវ និងជាពិសេសត្រូវពន្យល់ណែនាំអំពីនីតិវិធីដល់ភាគីឲ្យបានយល់កាន់តែបច្បាស់គុណសម្បត្តិនៃការបំពេញកិច្ចនីតិវិធី ក៏ដូចជាគុណវិបត្តិប្រសិនបើមិនបានបំពេញនូវនីតិណាមួយនៃអាពាហ៍ពិពាហ៍របស់ពួកគេ។ កន្លងមកយើងខ្ញុំសង្កេតឃើញថាសហព័ទ្ធខ្វះគឺមិនបានបំពេញកិច្ចនៃនីតិវិធីចប់សព្វគ្រប់នោះទេ ហើយនៅពេលដែលមានបញ្ហានៅក្នុងគ្រួសារកើតឡើងពួកគេតែងតែទៅ

សាលាឃុំ សង្កាត់ដើម្បីឲ្យជួយដោះស្រាយ ប៉ុន្តែអាជ្ញាធរឃុំ សង្កាត់គឺពុំមានសមត្ថកិច្ចក្នុងការដោះស្រាយបញ្ហាដែលកើតឡើងនោះទេ ជាក់ស្តែងដូចជា ការសំលែងលះ ការបែងចែកទ្រព្យសម្បត្តិ ឬការគ្រប់គ្រងទទួលភារកិច្ចមើលថែកូនជាដើម ដោយសមត្ថកិច្ចទាំងនេះគឺជាសមត្ថកិច្ចរបស់តុលាការជាអ្នកមានសមត្ថកិច្ច។

ជាចុងក្រោយពួកខ្ញុំទាំងពីរនាក់ ក៏ដូចជាមិត្តនិស្សិតផ្សេងទៀតសូមណ្ឌមពរដល់អាជ្ញាធរមានសមត្ថិកិច្ច ក៏ដូចជាប្រជាពលរដ្ឋគប្បីបំពេញបែបបទតាមបទដ្ឋានគិយុត្តដែលបានចែងជាធរមានឲ្យបានត្រឹមត្រូវ ដើម្បីជៀសវាងមានបញ្ហាដែលបានកើតឡើងក្រោយពេលរៀបអាពាហ៍ពិពាហ៍រួចហើយ ធ្វើឲ្យមានវិវាទនៅក្នុងគ្រួសារដែលមិនអាចមានវិធីណាមួយដោះស្រាយបាន និងដើម្បីធានាបាននូវសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ, ២៤ កញ្ញា ១៩៩៣។
- ក្រមរដ្ឋប្បវេណីលេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។
- ច្បាប់ឯកពន្ធភាព នស/រកម/១០០៦/០២៦,២១ តុលា ២០០៦
- អនុក្រិត្យស្តីពីអត្រានុកូលដ្ឋាន,លេខ១០៣ អនក្រ កប, ២៩ ធ្នូ ២០០០

## សៀវភៅបោះពុម្ព

- សេចក្តីកំណត់មាត្រានីមួយៗក្រមរដ្ឋប្បវេណី
- សៀវភៅ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍ លោកគ្រូ ឥត យឿន
- សៀវភៅមេរៀន អាពាហ៍ពិពាហ៍ និងគ្រួសារ សាស្ត្រាចារ្យបេក្ខបណ្ឌិតច្បាប់ គាម ម៉ារិទ្ធីយ៉ា

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១

- បណ្ណប្រកាសជាសាធារណៈ

## ឧបសម្ព័ន្ធទី២

- លិខិតបញ្ជាក់ភាពនៅលីវ, ពោះម៉ាយ, មេម៉ាយ
- ពាក្យសុំបញ្ជាក់ភាពនៅលីវ, ពោះម៉ាយ, មេម៉ាយ

## ឧបសម្ព័ន្ធទី៣

- សំបុត្រកំណើត
- សំបុត្របញ្ជាក់កំណើត
- សេចក្តីចម្លងសំបុត្រកំណើត
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត

## ឧបសម្ព័ន្ធទី៤

- សំបុត្រអាពាហ៍ពីពាហ៍
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍

## ឧបសម្ព័ន្ធទី៥

- សំបុត្រមរណភាព
- សេចក្តីចម្លងសំបុត្រមរណភាព

# ឧបសម្ព័ន្ធទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង ----------------------
ស្រុក ខណ្ឌ ----------------------
ឃុំ សង្កាត់ ----------------------
លេខ ----------------------

## បណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| រយៈពេលប្ដឹងជំទាស់ | | |
| នាមត្រកូល និងនាមខ្លួនឪពុក | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| នាមត្រកូល និងនាមខ្លួនម្ដាយ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |

បណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី............ ខែ...................... ឆ្នាំ............... ។

ធ្វើនៅ...................... ថ្ងៃទី.......... ខែ............... ឆ្នាំ..........

**មន្ត្រីអត្រានុកូលដ្ឋាន**

# ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚*៚៚

រូបថត

៤x៦

២ សន្លឹក

**រាជធានីភ្នំពេញ**

**រដ្ឋបាលខណ្ឌចំការមន**

**រដ្ឋបាលសង្កាត់ផ្សារដើមថ្កូវ**

**លេខ:....................... /២២**

ថ្ងៃ.....................ខែ.............ឆ្នាំ ថោះ បញ្ចស័កស័ក ព.ស២៥៦៧

ផ្សារដើមថ្កូវ.ថ្ងៃទី............ខែ............ឆ្នាំ២០២៣.

## <u>លិខិតបញ្ជាក់</u>

### ភាពនៅលីវ~ភាពពោះម៉ាយ~ភាពមេម៉ាយ

យោងពាក្យសុំបញ្ជាក់ភាព.......................ចុះថ្ងៃទី............ខែ.............ឆ្នាំ ២០២៣ របស់...........................

### យើងចៅសង្កាត់ផ្សារដើមថ្កូវ

សូមបញ្ជាក់ថា ឈ្មោះ........................................ភេទ................កើតនៅថ្ងៃ......................ទី.........ខែ..........

ឆ្នាំ................. នៅភូមិ...............................ឃុំ ឬ សង្កាត់......................... ស្រុក ឬ ខណ្ឌ...........................

ខេត្ត ឬ រាជធានី......................មុខរបរបច្ចុប្បន្ន.........................................................................មានទីលំនៅបច្ចុប្បន្ន

ផ្ទះលេខ.............ផ្លូវលេខ...............ក្រុមទី.........ភូមិ............សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ

មានស្ថានភាពផ្ទាល់ខ្លួនបច្ចុប្បន្នពិតជា..............................**នៅលីវ**..............................ប្រាកដមែន ។

លិខិតបញ្ជាក់នេះ ចេញអោយសាមីខ្លួន យកទៅប្រើប្រាស់ក្នុងការសុំរៀបអាពាហ៍ពិពាហ៍។

(លិខិតបញ្ជាក់នេះ មានសុពលភាពរយៈពេល ៣ ខែ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ)។

**ចៅសង្កាត់**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

៚៛៙

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.......................................ភេទ...............សញ្ជាតិ ខ្មែរ កើតនៅថ្ងៃទី......................
ខែ............ឆ្នាំ........................ស្ថានភាពផ្ទាល់ខ្លួន......................មុខរបរបច្ចុប្បន្ន...........................................
មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ....................ផ្លូវលេខ..................ក្រុមទី...........ភូមិ..............សង្កាត់ផ្សារដើមថ្កូវ
ខណ្ឌចំការមន រាជធានីភ្នំពេញ ។
ឪពុកឈ្មោះ................................( រស់ ឬស្លាប់ ) ថ្ងៃទី...........ខែ...........ឆ្នាំ............ មុខរបរៈ.......................
ម្តាយឈ្មោះ...............................( រស់ ឬស្លាប់ ) ថ្ងៃទី..........ខែ...........ឆ្នាំ............ មុខរបរៈ.......................

**គោរពជូន**

**មន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់**.................................

**កម្មវត្ថុ:** សំណើសុំរៀបអាពាហ៍ពិពាហ៍ ។

ដោយខ្ញុំបាទ-នាងខ្ញុំ បានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ.............................ភេទ..........................
សញ្ជាតិ..........កើតនៅឆ្នាំ................មុខរបរ..................................មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ..................
ផ្លូវលេខ.................ក្រុមទី............ភូមិ...................ឃុំ ឬ សង្កាត់........................ស្រុក ឬ ខណ្ឌ.......................
ខេត្ត ឬ រាជធានី........................................ ។

ខ្ញុំសូមអះអាងថា ខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់............................មេត្តាអនុញ្ញាតអោយខ្ញុំទាំងពីនាក់បានរៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ ។

ថ្ងៃ....................................ខែ.........................ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
ផ្សារដើមថ្កូវ.ថ្ងៃទី.............ខែ.....................ឆ្នាំ២០២៣.

**ស្នាមមេដៃសាម៉ីខ្លួន**

ឈ្មោះ....................................

ភ្ជាប់មកជាមួយនូវ:
- សៀវភៅស្នាក់នៅ ឬ សៀវភៅគ្រួសារ ចតចម្លង ១ សន្លឹក
-រូបថត ៤x៦ ២ សន្លឹក
-សំបុត្រកំណើត ចតចម្លង ១ សន្លឹក

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

៙៚*៚៙

**ពាក្យសុំបញ្ជាក់**

**ភាពនៅលីវ-ភាពពោះម៉ាយ-ភាពមេម៉ាយ**

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ...........................................ភេទ....................សញ្ជាតិ ខ្មែរ កើតនៅថ្ងៃទី..........
ខែ.............ឆ្នាំ.................នៅភូមិ...........................ឃុំ ឬ សង្កាត់ .................... ស្រុក ឬ ខណ្ឌ..................
ខេត្ត ឬ រាជធានី..........................មុខរបរបច្ចុប្បន្ន............................................មានទីលំនៅបច្ចុប្បន្ន
ផ្ទះលេខ.........ផ្លូវលេខ............ក្រុមទី............ភូមិ..........សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**គោរពជូន**

**លោក ចៅសង្កាត់ផ្សារដើមថ្កូវ**

**កម្មវត្ថុ:** សំណើសុំលិខិតបញ្ជាក់ភាព.................................. ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូមជំរាប លោកចៅសង្កាត់មេត្តាជ្រាបថា: បច្ចុប្បន្ន ខ្ញុំបាទ-នាងខ្ញុំ មានស្ថានភាពផ្ទាល់ខ្លួន................ហើយមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ.........................
ភេទ.........មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ............ផ្លូវលេខ...........ក្រុមទី........ភូមិ......................ឃុំ ឬ សង្កាត់
..............................ស្រុក ឬ ខណ្ឌ...................................ខេត្ត ឬ រាជធានី................................... ។

អាស្រ័យហេតុនេះ សូមលោកមេឃុំឬ **ចៅសង្កាត់** មេត្តាចេញលិខិតបញ្ជាក់អោយ ខ្ញុំនាទ-នាងខ្ញុំ ដើម្បីអាចរៀបអាពាហ៍ពិពាហ៍បាន ដោយអនុគ្រោះ ។

ដើម្បីជាសាក្ខីភាពនៃការអះអាងខាងលើ ខ្ញុំបាទ-នាងខ្ញុំ សូមផ្តិតមេដៃស្តាំ ទុកជាភស្តុតាង ។

ថ្ងៃ...................................ខែ.......................ឆ្នាំថោះបញ្ចស័ក ព.ស២៥៦៧

ផ្សារដើមថ្កូវ.ថ្ងៃទី.............ខែ.....................ឆ្នាំ២០២៣

**ស្នាមមេដៃសាមីខ្លួន**

បានឃើញ និងបញ្ជាក់ថា:

ឈ្មោះ.....................................ភេទ......មានទីលំនៅក្នុងភូមិ...........

ពិតជានៅលីវ-មេម៉ាយ-ពោះម៉ាយប្រាកដមែន ។

ថ្ងៃ...................................ខែ.......................ឆ្នាំថោះបញ្ចស័ក ព.ស២៥៦៧

ផ្សារដើមថ្កូវ.ថ្ងៃទី.............ខែ.....................ឆ្នាំ២០២៣

**មេភូមិ**.....

ឈ្មោះ.........................

# ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត ....................................
ក្រុង ស្រុក ខណ្ឌ ....................................
ឃុំ សង្កាត់ ....................................

លេខ ....................................................
សៀវភៅបញ្ជាក់កំណើតលេខ..............
ឆ្នាំ....................................................

# សំបុត្របញ្ជាក់កំណើត

| | | | |
|---|---|---|---|
| នាមត្រកូល | | | ភេទ |
| នាមខ្លួនអ្នកកើត | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួនអ្នកកើត | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស | | ....................................<br>.................................... | |

| ឪពុក ម្តាយ | ឪពុក | ម្តាយ |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស | ....................................<br>.................................... | ....................................<br>.................................... |

ធ្វើនៅ..................................ថ្ងៃទី..........ខែ............ឆ្នាំ..............

**មន្ត្រីអត្រានុកូលដ្ឋាន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត** ..........................................
**ក្រុង ស្រុក ខណ្ឌ** ..........................................
**ឃុំ សង្កាត់** ..........................................

# សេចក្តីចម្លងសំបុត្រកំណើត

| ចម្លងសំបុត្រកំណើតចេញពី | | សៀវភៅកំណើត<br>លេខ | សំបុត្រកំណើត<br>លេខ...........ចុះថ្ងៃទី........ខែ..........ឆ្នាំ............ |
|---|---|---|---|
| នាមត្រកូល | | | ភេទ |
| នាមខ្លួនទារក | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួនទារក | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស | | ..........................................<br>.......................................... | |

| ឪពុក ម្តាយទារក | ឪពុក | ម្តាយ |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស | ..........................................<br>.......................................... | ..........................................<br>.......................................... |
| ទីលំនៅពេលទារកកើត | | |

ធ្វើនៅ.....................................ថ្ងៃទី..........ខែ..............ឆ្នាំ................

**មន្ត្រី**.....................................................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត** ..........................................
**ក្រុង ស្រុក ខណ្ឌ** ..........................................
**ឃុំ សង្កាត់** ..........................................

# សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត

| | | | |
|---|---|---|---|
| ចម្លងសំបុត្របញ្ជាក់កំណើតចេញពី | | សៀវភៅបញ្ជាក់កំណើត លេខ | សំបុត្របញ្ជាក់កំណើត លេខ...........ចុះថ្ងៃទី........ខែ..........ឆ្នាំ............ |
| នាមត្រកូល | | | ភេទ |
| នាមខ្លួនអ្នកកើត | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួនអ្នកកើត | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | ........................................ ........................................ | |

| ឪពុក ម្តាយ | ឪពុក | ម្តាយ |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | ........................................ ........................................ | ........................................ ........................................ |

ធ្វើនៅ..........................................ថ្ងៃទី.............ខែ.....................ឆ្នាំ...............

**មន្ត្រី**..........................................................................

# ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| | |
|---|---|
| រាជធានី ខេត្ត ........................................ | លេខ................................................................ |
| ក្រុង ស្រុក ខណ្ឌ ........................................ | សៀវភៅអាពាហ៍ពិពាហ៍លេខ................................ |
| ឃុំ សង្កាត់ ........................................ | ឆ្នាំ................................................................ |

# សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល | | | |
| នាមខ្លួន | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួន | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | ................................<br>................................ | ................................<br>................................ |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |

| អំពីឪពុក ម្តាយ | ខាងប្តី | ខាងប្រពន្ធ |
|---|---|---|
| នាមត្រកូល និង នាមខ្លួនឪពុក | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| នាមត្រកូល និង នាមខ្លួនម្តាយ | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |

ធ្វើនៅ.................................... ថ្ងៃទី.......... ខែ.............. ឆ្នាំ..................

**មន្ត្រីអត្រានុកូលដ្ឋាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ..........................................
ក្រុង ស្រុក ខណ្ឌ ..........................................
ឃុំ សង្កាត់ ..........................................

# សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍

| ចម្លងសំបុត្រអាពាហ៍ពិពាហ៍ចេញពី | សៀវភៅអាពាហ៍ពិពាហ៍<br>លេខ | សំបុត្រអាពាហ៍ពិពាហ៍<br>លេខ..............ចុះថ្ងៃទី........ខែ.............ឆ្នាំ.............. |
|---|---|---|
| **អំពីប្តី ប្រពន្ធ** | **ប្តី** | **ប្រពន្ធ** |
| នាមត្រកូល | | |
| នាមខ្លួន | | |
| ជាអក្សរឡាតាំង – នាមត្រកូល | | |
| ជាអក្សរឡាតាំង – នាមខ្លួន | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស | ..............................<br>.............................. | ..............................<br>.............................. |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ | | |
| **អំពីឪពុក ម្តាយ** | **ខាងប្តី** | **ខាងប្រពន្ធ** |
| នាមត្រកូល និង នាមខ្លួនឪពុក | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| នាមត្រកូល និង នាមខ្លួនម្តាយ | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |

ធ្វើនៅ...................................ថ្ងៃទី............ខែ...................ឆ្នាំ...............

មន្ត្រី..............................................................

# ឧបសម្ព័ន្ធទី៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត** ........................................
**ក្រុង ស្រុក ខណ្ឌ** ........................................
**ឃុំ សង្កាត់** ........................................

**លេខ**........................................................
**សៀវភៅមរណភាពលេខ**............................
**ឆ្នាំ**........................................................

# សំបុត្រមរណភាព

| | | | |
|---|---|---|---|
| នាមត្រកូល | | | ភេទ |
| នាមខ្លួនសព | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួនសព | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស | | ..........................................<br>.......................................... | |
| ស្ថានភាពសព<br>នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ | | | |
| នាមត្រកូល និង នាមខ្លួនឪពុកសព | | | សញ្ជាតិ |
| ជាអក្សរឡាតាំង | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| នាមត្រកូល និង នាមខ្លួនម្តាយសព | | | សញ្ជាតិ |
| ជាអក្សរឡាតាំង | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |

ធ្វើនៅ.................................... ថ្ងៃទី..........ខែ..............ឆ្នាំ..................

**មន្ត្រីអត្រានុកូលដ្ឋាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ........................................
ក្រុង ស្រុក ខណ្ឌ ........................................
ឃុំ សង្កាត់ ........................................

# សេចក្តីចម្លងសំបុត្រមរណភាព

| ចម្លងសំបុត្រមរណភាពចេញពី | | សៀវភៅមរណភាព<br>លេខ | សំបុត្រមរណភាព<br>លេខ............ចុះថ្ងៃទី.......ខែ...............ឆ្នាំ.............. |
|---|---|---|---|
| នាមត្រកូល | | | ភេទ |
| នាមខ្លួនសព | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួនសព | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ<br>រាជធានី ខេត្ត ប្រទេស | | ..........................................................................................<br>.......................................................................................... | |
| ស្ថានភាពសព<br>នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ | | | |
| នាមត្រកូល និង នាមខ្លួនឪពុកសព | | | សញ្ជាតិ |
| ជាអក្សរឡាតាំង | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| នាមត្រកូល និង នាមខ្លួនម្តាយសព | | | សញ្ជាតិ |
| ជាអក្សរឡាតាំង | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |

ធ្វើនៅ.......................................ថ្ងៃទី............ខែ...................ឆ្នាំ..............

មន្ត្រី..................................................................